# អារម្ភកថា

-ដោយសេចក្តីជ្រះថ្លាក្នុងព្រះធម៌នៃព្រះដ៏មានព្រះភាគ

-ដោយបរិសទ័មួយចំនួនមិនសូវយកចិត្តទុកដាក់ប្រតិបត្តិ ក្នុង ព្រះសទ្ធម្ម

-ដោយចង់ឱ្យព្រះសទ្ធម្មជ្រាបចូលក្នុងសន្តាននៃសព្វសត្វ

ហេតុការណ៍ទាំងអស់នេះ ទើបជម្រុញឱ្យខ្ញុំព្រះករុណាអាត្មាភាព ឆ្លៀតឱកាសដ៏មមាញឹក រៀបរៀងសៀវភៅមួយក្បាលនេះឡើង ដោយឱ្យឈ្មោះថា :

## " តើ នរកមានដែរឬទេ ? "

បន្ទាប់ពីបានរៀបរៀងចប់ ខ្ញុំព្រះករុណាអាត្មាភាព បានយកទៅជូនលោកអគ្គបណ្ឌិត ប៊ុត សាវង្ស ឱ្យជួយកែសម្រួល ឃើញថាត្រឹមត្រូវហើយ ។

តែទោះជាយ៉ាងណាក៏ដោយចុះ ខ្ញុំព្រះករុណាអាត្មាភាព នឹងទទួលនូវការរិះគន់អំពីសំណាក់មិត្តអ្នកអានទាំងអស់ បើសិនជាមានការខ្វះខាត ។

សូមសព្វសត្វទាំងអស់ បានក្រេបយកនូវឱជារស នៃព្រះសទ្ធម្ម ដែលជាឱសថដ៏ត្រជាក់កំពូលក្នុងលោក ។

ពោធិ៍សាត់ ថ្ងៃអាទិត្យ ១៥កើត ខែ ជេស្ឋ ឆ្នាំ មមី ព-ស ២៥៤៦

ភិក្ខុ វជិរប្បញ្ញោ **សាន សុជា**

# មាតិកាធម៌


| ល.រ | ឈ្មោះធម៌ | ទំព័រ |
|---|---|---|
| ១ | កំណើតសត្វ៤យ៉ាង | ១ |
| ២ | អធិប្បាយកំណើតសត្វទី៤ | ២ |
| ៣ | ភ្លើងនរកបច្ចុប្បន្ន | ៤ |
| ៤ | ជីវិតជារបស់ក្តៅ | ៥ |
| ៥ | ភ្លើតភ្លើនក្នុងភ្លើងនរក | ៨ |
| ៦ | អ្វីជាគ្រឿងបាំងមិនឱ្យឃើញនរក | ១៤ |
| ៧ | បញ្ហានរកបរលោក | ១៨ |
| ៨ | តើបាបនិងបុណ្យនៅត្រង់ណា | ២១ |
| ៩ | រឿងចន្ទសូករិក | ២៥ |
| ១០ | ឧបមាទុក្ខក្នុងនរក | ២៦ |
| ១១ | រឿងព្រះមាល័យ | ២៩ |
| ១២ | ទេវទូតទី១ | ៣៥ |
| ១៣ | ទេវទូតទី២ | ៣៧ |
| ១៤ | ទេវទូតទី៣ | ៤០ |
| ១៥ | ទេវទូតទី៤ | ៤២. |

| | | |
|---|---|---|
| ១៦ | ទេវទូតទី៥ | ៤៤ |
| ១៧ | សេចក្តីទុក្ខក្នុងនរកបរលោក | ៤៩ |
| ១៨ | ហេតុអ្វីសត្វនរកមិនស្លាប់? | ៥៥ |
| ១៩ | ជានអជានបញ្ហា | ៥៩ |
| ២០ | បំនកស្រាយចម្ងល់ខ្លះៗ | ៦២ |
| ២១ | និគមគាថា | ៦៦ |
| ២២ | សំនោករបស់យាយ ( កំណាព្យ ) | ៦៨ |
| ២៣ | មានះរបស់តា ( កំណាព្យ ) | ៧១ |
| ២៤ | មនុស្សរណោរាទ( កំណាព្យ ) | ៧៣ |
| ២៥ | នាមសប្បុរសអ្នកចេញថ្លៃបោះពុម្ព | |

# កំណើត ៤ យ៉ាង

មុននឹងលើកយកបញ្ហានរកមកនិយាយ សូមញាតិញោម បងប្អូនប្រុសស្រី មិត្តអ្នកអានទាំងឡាយ សិក្សាអំពីកំណើតសត្វ ឱ្យបានចេះដឹងជាមុនសិន ។ តាមពិតកំណើតសត្វលោកមានច្រើន ប្រភេទណាស់ ដូចដែលព្រះដ៏មានបុណ្យរបស់យើងទ្រង់ត្រាស់ថា (សត្តា-អនន្តា) ប៉ុន្តែក្នុងបញ្ហានេះដែរ ព្រះអង្គក៏ទ្រង់បានបំព្រួញ ឱ្យខ្លីមកដើម្បីឱ្យយើងទាំងអស់គ្នាងាយស្រួលសិក្សា គឺមានត្រឹម តែ៤ ប្រភេទប៉ុណ្ណោះ គឺ :

ទី ១ : **អណ្ឌជៈ** សំដៅយកសត្វទាំងឡាយណា ដែលមក អាស្រ័យក្នុងស៊ុតហើយចោះទំលាយសំបកស៊ុតចេញមក ដូចជា: សត្វចាប លលក មាន់ ទា ជាដើម ។

ទី ២ : **ជលាពុជៈ** សំដៅយកសត្វទាំងឡាយណា ដែល សម្រាលចេញពីផ្ទៃមេឬផ្ទៃម្តាយដូចជា:សត្វមនុស្ស គោ ក្របី ឆ្កែ ឆ្មា ដំរី សេះ ជាដើម ។

ទី ៣ : **សំសេទជៈ** សំដៅយកសត្វទាំងឡាយណា ដែល កើតមកពីត្រីស្អុយ សាកសព ឬ ក្នុង វត្ថុជូរផ្អូម ដូចជា : សត្វដង្កូវជាដើម ។

ទី ៤ : **ឧបបាតិកៈ** សំដៅយកសត្វទាំងឡាយណា ដែលកើតឡើងឯង១ ដូចជាទេវតា នរក ប្រេតជាដើម ។

បើសង្កេតមើលមាតិកាធម៌ខាងលើចាប់ពីមាតិកាទី១ រ-ហូតដល់ទី៣ ខ្ញុំជឿជាក់ថាញាតិញោមបងប្អូនប្រុសស្រី មិត្តអ្នកអានពិតជាមិនឆ្ងល់ទេ ប៉ុន្តែរឿងដែលអាចកំបាំង ហើយគួរឱ្យងឿងឆ្ងល់នោះ គឺមាតិកាធម៌ទី ៤ គឺ កំណើតសត្វទី ៤ ដូច្នេះសូមឆ្លៀតឱកាសលើកយកកំណើតសត្វទី៤ មកអធិប្បាយដូចតទៅ ។

## អធិប្បាយកំណើតសត្វទី ៤

នៅក្នុងព្រះអដ្ឋកថា បានសំដែងថាៈបណ្ដាសត្វទាំងឡាយ សត្វប្រភេទមួយកើតឡើងដោយចោះសំបកស៊ុតចេញមក ប្រ-ភេទមួយកើតឡើងដោយអាស្រ័យវត្ថុស្មោកគ្រោក ប្រភេទមួយកើតឡើងដោយការសម្រាលចេញពីផ្ទៃមេឬផ្ទៃម្ដាយ ។ តែសំ-រាប់ឧបបាតិកៈកំណើត គឺសំដៅដល់សត្វដែលកើតឡើងដោយពុំបានអាស្រ័យហេតុ ដូចសត្វ ៣ ប្រភេទខាងលើនោះឡើយ ។ សត្វពួកនេះ វេលាកើតក៏កើតឡើងឯង១ មានរូបកាយធំឡើង

ភ្លាម១។ សេចក្តីអធិប្បាយយ៉ាងនេះ យើងគប្បីយល់ចូលចិត្តថា ឧបបាតិកៈកំណើត គឺជាកំណើតប្រភេទមួយ ដែលកើតឡើង ដោយមិនចាំបាច់មេបាឱ្យកំណើតឡើយ។ អាស្រ័យទៅលើពុទ្ធ ភាសិតច្រើនកន្លែង ស្តែងឱ្យឃើញថា ពួកទេវតានិងពួកនរក សុទ្ធតែជាឧបបាតិកៈកំណើត ។

ម្យ៉ាងទៀតក្នុងអដ្ឋកថាដដែលបានតួយ៉ាងថា ពួកទេវតា ជាឧបបាតិកៈកំណើតនេះ បានដល់ទេវតាក្នុងចាតុម្មហារាជិកា រហូតដល់ទេវតាឋានខ្ពស់ៗឡើងទៅជាលំដាប់។ ចំណែកភុម្មទេ-វតា គឺទេវតាដែលស្ថិតនៅលើផែនដីនេះ រមែងប្រព្រឹត្តទៅបាន ទាំង ៤ កំណើត ហើយលោកបានបញ្ជាក់បន្ថែមថា មនុស្សខ្លះក៏ជា ឧបបាតិកៈកំណើតដែរ (ដូចជានាងចិញ្ចាជាដើម)។ ក្នុងសេចក្តី នេះខ្ញុំមិនបានអធិប្បាយឱ្យពិស្តារទេ បើមិត្តអ្នកអានចង់យល់ច្បាស់ អំពីរឿងឧបបាតិកៈកំណើតនេះ សូមនិមន្តនិងអញ្ជើញតាមដាន នៅក្នុងអគ្គញ្ញសូត្រទៀតចុះ ។

# ភ្លើងនរកបច្ចុប្បន្ន

ការសំដែងអំពីនរក ឬ ក៏ស្ថានសួគ៌ មិនមែនមានតែក្នុងព្រះពុទ្ធសាសនាទេ ក្នុងសាសនាដទៃទៀតក៏មាននិយាយដែរ ប៉ុន្តែអ្នកគោរពបូជាសាសនាភាគច្រើន តែងប្រកាន់ថា នរកមានតែនៅក្នុងលោកខាងមុខឯណោះទេ ប៉ុន្តែមិនបានសិក្សាឱ្យយល់ចូលចិត្តថា ក្នុងលោកនៃជីវិតសព្វថ្ងៃនេះឯង ឋានសួគ៌ក៏មាន ឋាននរកក៏មានដែរ ។ នៅក្នុងអាទិត្តបរិយាយសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា "ម្នាលភិក្ខុទាំងឡាយ ! ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ត្រូវភ្លើងដុតកំដៅរាល់ថ្ងៃ ។ តើភ្លើងនោះជាអ្វី ? ភ្លើងនោះគឺ រាគៈ ទោសៈ មោហៈ នេះ យើងពោលថាជាភ្លើង ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ នេះក៏យើងពោលថាជាភ្លើង " ។

យោងទៅតាមពុទ្ធភាសិតខាងលើនេះ ស្តែងឱ្យយើងឃើញយ៉ាងច្បាស់ថា នរកមាននៅក្នុងជីវិតនេះឯង នរកក៏មាននៅក្នុងចិត្តយើងនេះឯង ។

គប្បីយល់ចូលចិត្តបន្ថែមទៀតថា **កន្លែងណាដែល**

**ប្រាសចាកកុសល ទីនោះឯងគឺជានរក** ។

# ជីវិតជារបស់ក្តៅ

តើអ្វីជាជីវិត ? ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ និងវេទនាទាំង-ឡាយដែលសោយតាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ គឺជាតួជីវិត ជារបស់ក្តៅ ។ តើក្តៅព្រោះអ្វី ? ក្តៅព្រោះភ្លើងកិលេស គឺ រាគៈ ទោសៈ មោហៈ ។

នាពេលបច្ចុប្បន្ននេះ បើទោះជាគ្មានអ្នកណាប្រាប់ ក៏យើងអាចដឹងបានថាៈ សត្វលោកកំពុងរស់នៅក្នុងកំដៅ ហើយកំដៅនេះមានកំនើនកើនជាងមុន ១ ដង ជា ៥ ដង ឯណោះ។ សភាពទាំងអស់នេះក៏ព្រោះតែភ្លើង រាគៈ ទោសៈ មោហៈ ដែលអាស្រ័យនៅក្នុងចិត្តរបស់សត្វលោក កាន់តែមានចំហេះខ្លាំងឡើងៗ ដោយ

ហេតុថា សត្វលោកកាន់តែឆ្លាត មានល្បិចកលពិសពុល ក្នុងការផ្គុំភ្លើងតណ្ហា ឱ្យកាន់តែមានកម្លាំងខ្លាំងឡើងៗជាលំដាប់។ សត្វលោករឹតតែគ្មានដឹង គ្មានជំនឿ គ្មានប្រកាន់យកថា ការពន្លត់ភ្លើង រាគៈ ទោសៈ មោហៈ គឺជាចំណុចដ៏ត្រជាក់ដ៏កំពូលរបស់ជីវិតនោះទេ ផ្ទុយមកវិញគេច្រើនតែស្វែងរកសេចក្តីសប្បាយរីករាយលើបញ្ចកាមគុណ ដែលជាការពង្រីកភ្នក់ភ្លើងឱ្យកាន់តែធំដោយគំនិតបញ្ឆេះច្រើនជាងគំនិតពន្លត់។ សកលលោកបានក្លាយទៅជាលោកដែលមានកំដៅទាំងមនុស្សទាំងសត្វទាំងសកលធាតុក៏ព្រោះតែមនុស្សក្នុងពិភពលោកនាំគ្នាស្ទាបអង្អែលនូវបញ្ចកាមគុណ នាំគ្នាបំរើសេចក្តីសប្បាយបោកប្រាស់ ប្រកបដោយចិត្តពោរពេញទៅដោយរាគៈ ទោសៈ មោហៈ លើសពីសម័យមុន ១ ជា ១០ ដង ឬ១ ជា ២០ដង ក៏អាចថាបាន ។ សព្វថ្ងៃនេះ មនុស្សបាននាំគ្នាពពាក់ពពូនជំពាក់ជំពិនលើអំពើដុតកំដៅខ្លួនឯង គឺនាំគ្នាថ្វេរ នាំគ្នាជូរចត់ក្នុងជីវិតរបស់ខ្លួន គេនាំគ្នាបង្កើនកិលេសរបស់ខ្លួន គេប្រាថ្នាលើកខ្លួនរបស់គេជាម្ចាស់ពិភពលោក។

ជាងនេះទៅទៀត គំនិតរបស់មនុស្សម្នាក់ៗ តែងមានការប្រកាន់យកនូវរបស់មិនទៀង ជាទុក្ខ ជាអនត្តា ថាជារបស់ទៀង

ជាសុខ ជាអត្តា ។ ប៉ុន្តែការប្រកាន់ និង គំហើញរបស់គេទាំងនោះ លទ្ធផលចុងក្រោយ គឺសំណើចលាយទំនួញ សំអប់លាយសំឡាញ់ សម្លួតលាយកំណាចជាដើម ដែលផ្លាស់ប្តូរគ្នាទៅវិញទៅមកឥតឈប់ឈរ ស្ថិតក្រោមលក្ខណៈដុតបំផ្លាញខ្លួនឯងដោយវិធីផ្សេងៗ យ៉ាងមុខគួរឱ្យសង្វេគខ្លោចផ្សាដោយគ្មានដឹងខ្លួនឡើយ ។

សូមមេត្តាពិចារណានូវពុទ្ធភាសិតមួយកន្លែងទៀតដូចខាងក្រោមៈ

*"មិនមានភ្លើងអ្វី( ក្តៅ) ស្មើដោយរាគៈ*

*មិនមានចង្រៃអ្វី( ឱ្យទោស) ស្មើដោយទោសៈ*

*មិនមានសំណាញ់អ្វី( ស្មុគ្រស្មាញ) ស្មើដោយមោហៈ*[(១)]

តាមពុទ្ធភាសិតខាងលើនេះ ស្តែងឱ្យយើងឃើញកាន់តែច្បាស់ថាៈ សូម្បីតែភ្លើងពិតៗ ក៏មិនអាចមានកំដៅស្មើដោយភ្លើងរាគៈបានឡើយ ។ ដូច្នេះ នរកក្នុងលោកនេះ គឺជានរកកាចសាហាវជាងនរកស្រុកខ្មោច ព្រោះភ្លើងដ៏ក្តៅគឺរាគៈ ទោសៈ មោហៈ នេះវាជាក្បាលម៉ាស៊ីនដឹកនាំឬបង្កើតឱ្យមាននរកស្រុកខ្មោច ។

---

( ១) សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា មលវគ្គ

# ភ្លើតភ្លើនក្នុងភ្លើងនរក

< នរក >ប្រែថារណ្តៅ បានដល់កាមគុណទាំងឡាយ ដែលសាមញ្ញជនផងទាំងពួងតែងឱ្យតម្លៃ និងតែងតែលិទ្ធភ្លក់ មិនជិនណាយ ថ្វីបើគេដឹងថា ការប្រព្រឹត្តិបែបនេះ លទ្ធផលគឺ សំណើចលាយទឹកភ្នែក ស្រឡាញ់លាយស្អប់ យ៉ាងណាក៏ដោយ ក៏ពួកគេនៅតែស៊ូទ្រាំ ព្រោះគេមិនបានស្គាល់ច្បាស់នូវគុណតម្លៃ នៃព្រះសទ្ធម្ម ប្រៀបបីដូចជាសត្វមមាចដែលសប្បាយភ្លើតភ្លើន ជាមួយព្រះអគ្គីដូច្នោះដែរ។ សេចក្តីសុខនៅក្នុងកាមគុណទាំងឡាយដែលអ្នកផងទាំងពួងគេប្រៀបប្រដូចទៅនឹងស្ថានសួគ៌លោកីយ៏នោះ ក្នុងទស្សនៈនៃព្រះសម្មាសម្ពុទ្ធទ្រង់ឃើញថាជាស្ថាន នរកពិតៗ។

សូមពិចារណាន័យសេចក្តីក្នុងរឿងសានុសាមណេរត្រង់ឃ្លា ដែលសាមណេរមានប្រាថ្នាចង់លាចាកសិក្ខាបទ តែត្រូវមាតាឃាត់ថា :

" សានុកូន! ម្តាយបានស្រង់អ្នកឱ្យឃ្លាតចាកនរកហើយ តើអ្នកចង់ធ្លាក់នរកទៀតឬ ? "

ដូច្នេះកាមគុណក្នុងលោកគឺជាភ្លើងនរកដែលតែងតែដុតកំដៅឬកាប់ចិញ្ច្រាំសន្តានចិត្តរបស់សត្វលោកដែលអវិជ្ជាគ្របសង្កត់។ សូមនិមន្ត និងអញ្ជើញសិក្សានូវរឿង ១ ដូចតទៅ :

សម័យមួយព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់គង់ប្រថាប់ក្នុងវត្តវេឡុវ័នទៀបក្រុងរាជគ្រឹះ។ គ្រានោះប្រធានអ្នករបាំឈ្មោះតាលបុត្រចូលទៅគាល់ព្រះអង្គ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះអង្គថា:

"បពិត្រព្រះអង្គដ៏មានជោគ ខ្ញុំព្រះអង្គបានឮគ្រូ របាំក្នុងគ្រាមុននិយាយគ្នាថា អ្នករបាំណាធ្វើឱ្យអ្នកមើលមានសេចក្តីសប្បាយរីករាយចិត្តនៅលើវេទិកានៃល្ខោនឬ នៅកណ្តាលទីប្រជុំជន ដោយរឿងពិតខ្លះមិនពិតខ្លះ អ្នករបាំនោះ កាលណាធ្វើមរណកាលទៅហើយរមែងបានទៅកើតក្នុងស្ថានសួគ៌ បានជាសម្លាញ់នៃពួកទេវតាអ្នកមានសេចក្តីរីករាយភ្លើតភ្លើន ។ បពិត្រព្រះអង្គមានជោគក្នុងរឿងនេះ តើព្រះអង្គទ្រង់យល់ដូចម្តេចដែរ ? ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់តបថា :

"កុំឱ្យនិយាយរឿងនេះឡើយ កុំសួរយើងរឿងនេះឡើយ តាលបុត្រ ! "។

តាលបុត្រប្រធានអ្នករបាំ បានទទូចក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគជាលើកទី ២ តែព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បដិសេធដូចមុន ។ កាលបើនាយតាលបុត្រ បានក្រាបបង្គំទូលសួរជាលើកទី ៣ ទើបព្រះអង្គទ្រង់ត្រាស់ថា :

កាលបើហាមមិនស្តាប់ដូចនេះ ជាច្រើនដងហើយ យើងនឹងនិយាយឱ្យអ្នកស្តាប់ ម្នាលតាលបុត្រ តាមធម្មតាសត្វទាំងឡាយសុទ្ធតែមានរាគៈ ត្រូវខ្ជាប់ដោយសំណាញ់នៃរាគៈ ជាបុគ្គលមានទោសៈ ត្រូវខ្ជាប់ដោយសំណាញ់នៃទោសៈ មានមោហៈ ត្រូវខ្ជាប់ដោយសំណាញ់នៃមោហៈជាស្រេចហើយ វត្ថុធាតុណាដែលជានុយនៃរាគៈ ទោសៈ មោហៈ អ្នករបាំក៏ព្យាយាមលើកយកវត្ថុធាតុដែលជានុយនៃរាគៈ ទោសៈ មោហៈ នោះទៅព្យួរត្រដាងកណ្តាលវេទិកានៃល្ខោនឬកណ្តាលទីប្រជុំជន ឱ្យមនុស្សទាំងឡាយកើតរាគៈ ទោសៈ មោហៈ រឹងរិតតែច្រើនឡើងទៀត ខ្លួនឯងជាមនុស្សធ្លាក់ចុះទៅក្នុងសេចក្តីប្រមាទ សេចក្តីស្រវឹងទៅហើយថែមទាំងធ្វើឱ្យមនុស្សដទៃស្រវឹង ប្រមាទតាមខ្លួនច្រើនទៀត។ ម្នាលតាលបុត្រ នរកឈ្មោះ បហាសៈ មានប្រាកដ ដូច្នេះកាលគេ

ធ្វើមរណកាលទៅហើយ អ្នករបាំនោះរមែងចូលទៅកើតក្នុងនរក មិនខាន ។

ប្រសិនបើគេមានទិដ្ឋិយ៉ាងនេះថា " អ្នករបាំរូបណាធ្វើឱ្យមនុស្សសើចសប្បាយក្នុងកណ្ដាលទីប្រជុំជន ឬលើវេទិកានៃល្ខោនដោយរឿងពិតខ្លះ មិនពិតខ្លះ អ្នករបាំរូបនោះ កាលណាធ្វើមរណកាល ទៅរមែងចូលទៅដល់ស្ថានសួគ៌ បានជាសម្លាញ់នៃពួកទេវតា អ្នកសម្បូណ៌សេចក្ដីសប្បាយរីករាយ" ។ គំហើញរបស់គេនោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ម្នាលតាលបុត្រ សម្រាប់បុគ្គលមានចិត្តជាមិច្ឆាទិដ្ឋិយ៉ាងនេះ យើងពោលថា គេនឹងទៅកាន់គតិ ២ យ៉ាង១ណាមួយ គឺនរក ឬ សត្វតិរច្ឆាន ។

ក្រោយពេលដែលព្រះបរមគ្រូទ្រង់ត្រាស់ដូច្នេះហើយ នាយតាលបុត្រប្រធានអ្នករបាំក៏ស្រែកទ្រហោយំ ។ ព្រះអង្គទ្រង់ត្រាស់ថា យើងប្រាប់អ្នកហើយ ថាកុំសួរយើងក្នុងរឿងនេះ តែអ្នកមិនស្ដាប់យើងសោះ ។ តាលបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏មានជោគ ខ្ញុំព្រះអង្គមិនបានយំ ព្រោះហេតុដែលព្រះអង្គទ្រង់ត្រាស់ដូច្នេះឡើយ តែខ្ញុំព្រះអង្គយំព្រោះឈឺចិត្ត ដោយត្រូវគ្រូរបាំបោកបញ្ឆោតមកជាយូរហើយ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះ

ធម្មទេសនារបស់ព្រះអង្គពិរោះណាស់ ដូចជាគេបើកភាជនៈដែលផ្កាប់ឱ្យផ្ងារឡើង ឬដូចជាគេប្រាប់ឱ្យស្គាល់នូវវត្ថុដែលត្រូវគេបិទបាំង ឬដូចជាប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬដូចជាទ្រោលប្រទីបក្នុងទីដែលងងឹត ដើម្បីឱ្យបុគ្គលមានភ្នែកល្អបានឃើញរបស់ផ្សេងៗ។ ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណៈ ខ្ញុំព្រះអង្គសូមបព្វជ្ជានិងឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។

ក្រោយមកនាយគាលបុត្រប្រធានអ្នករបាំ ក៏បានបួសក្នុងសំណាក់នៃព្រះបរមសាស្ដាចារ្យ ហើយមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល បានជាព្រះអរហន្តមួយអង្គក្នុងព្រះពុទ្ធសាសនា ។

សូមយកបញ្ញាដ៏ស្អាតមកពិចារណានូវពុទ្ធភាសិតមួយកន្លែងទៀតដូចតទៅ :

"គួរ[(១)] បើសប្បាយរីករាយ គួរបើសប្បាយភ្លើតភ្លើនអ្វីហ្ន៎! ក្នុងលោកជាទីនៅអាស្រ័យដែលកំពុងត្រូវភ្លើងឆេះសន្ធោសន្ធៅជាប្រក្រតីយ៉ាងនេះ" តាមន័យនេះ **មហាសនរតេ** គឺមានទាំង

(១) សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ជរាវគ្គ

ក្នុងលោកនេះនិងលោកខាងមុខ ។ **មហាសនរក** បច្ចុប្បន្នយើងអាច និយាយដោយវាចាកំប្លែងគឺសំដៅយករោងភាពយន្ត រោងល្ខោន កន្លែងរាំរែក ដែលនាំឱ្យកើតភ្លើងកិលេស គឺ រាគៈ ទោសៈ និង មោហៈនោះឯង ។ ប៉ុន្តែពពួកសាមញ្ញជនដែលប្រកបដោយសេចក្តី ត្រេកត្រអាល ស្ទើរទាំងពិភពលោកគេមិនយល់ថា ភាវៈយ៉ាង នេះគឺជានរកទេ គេមិនព្រមទទួលស្គាល់ថាខ្លួនគេនៅក្នុងនរក ឡើយ ។ ចំណែកព្រះអរិយបុគ្គលទាំងឡាយលោកមើលឃើញ យ៉ាងច្បាស់ថា កាមគុណគឺជានរក ចំណុចនេះសមទៅនឹងសេចក្តី ក្រាបទូលព្រះសម្មាសម្ពុទ្ធបរមគ្រូ របស់ព្រះសារីបុត្តថា ៖

" បពិត្រព្រះអង្គមានជោគ ព្រះខីណាស្រពទាំងឡាយ រមែងមើលឃើញយ៉ាងជាក់ច្បាស់ដោយបញ្ញាថា កាមទាំងឡាយ ប្រៀបដូចជារណ្តៅភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ " ។

តាមន័យសុភាសិតខាងលើនេះស្តែងឱ្យយើងឃើញថា ផ្អែកទៅលើសច្ចធម៌នៃធម្មជាតិ និងបុគ្គលដែលមានចិត្តខ្ពស់ ត្បូ យ៉ាងដូចជាព្រះអរិយបុគ្គល ទើបលោកមើលឃើញយ៉ាងច្បាស់ថា បុគ្គលដែលបណ្តោយចិត្តឱ្យជ្រប់ងប់ក្នុងវត្ថុធាតុទាំងឡាយមាន

បញ្ចកាមគុណជាដើម តែងបានទទួលផលក្ដៅក្រហាយដល់ថ្នាក់ត្រឹមណា១នោះ ។

សូម្បីតែក្នុងបច្ចុប្បន្ននេះ ពួកសាមញ្ញជនទាំងនោះ បានធ្លាក់នរកជាស្រេចទៅហើយ បើដូច្នេះមិនចាំបាច់ត្រូវសង្ស័យថាតើពេលដែលគេស្លាប់ទៅត្រូវទៅកើតក្នុងនរកបរលោកឬក៏អត់នោះទេ ។ អាស្រ័យហេតុនេះ ទើបព្រះជិនស្រីទ្រង់ត្រាស់ថា :

"សម្រាប់បុគ្គលដែលមានសេចក្ដីយល់ឃើញខុសបែបនេះ ក៏សម្រេចបានថា កាលណាគេធ្វើមរណកាលទៅ បើមិនទៅកាន់នរក ក៏គង់តិរច្ឆាន" ។

# អ្វីជាគ្រឿងបាំងមិនឱ្យឃើញនរក ?

សត្វលោកដែលមិនបានយល់ចូលចិត្តនូវព្រះសទ្ធម្ម គេរមែងជ្រប់ងប់នៅក្នុងលោកនេះ គេខ្វល់ខ្វាយក្នុងជីវិត ជាប់ជំពាក់នៅក្នុងសេចក្ដីប្រាថ្នា តូចចិត្តចំពោះភាពក្រលំបាកតោកយ៉ាក តែគេក៏ក្ដៅក្រហាយពីព្រោះតែទ្រព្យសម្បត្តិដែលខ្លួនហួង

ហែងរក្សាផងដែរ គេខ្វល់ខ្វាយនៅក្នុងរឿងទ្រព្យរបស់ ប៉ុន្តែគេមិនបានដឹងថា ទ្រព្យធនដែលជាវត្ថុកាមទាំងអស់គឺជាអន្ទាក់ដ៏សាហាវនោះទេ។ ម្យ៉ាងទៀត ហេតុតែគេមិនបានមើលឃើញនិងយល់ច្បាស់ថា "តើនរកមានដែរឬទេ ?" នោះ ព្រោះគ្រាប់ព្រួញដែលមានពិសដ៏កាចសាហាវ គឺកិលេស តណ្ហា ឧបាទាន បានមុតចូលស៊ប់ទៅក្នុងខ្លួនរបស់គេអស់កាលជាអង្វែងមកហើយ។ ដោយអំណាចពិសនៃគ្រាប់ព្រួញនេះ គេបានទទួលការចុកចាប់ឈឺផ្សាយ៉ាងខ្លាំងក្លា តែគេមិនដឹងធ្វើយ៉ាងណា ដើម្បីដកព្រួញពិសនោះចេញពីខ្លួនគេឡើយ។ សត្វលោកទាំងឡាយស្អប់ខ្ពើមសេចក្តីទុក្ខណាស់ ចង់បំបាត់សេចក្តីទុក្ខណាស់ តែគេខ្វះខាតមធ្យោបាយសម្រាប់អនុវត្ត។ ពេលវេលាចេះតែកន្លងទៅឥតឈប់ឈរ ដំបៅលើវិញ្ញាណរបស់គេចេះតែបញ្ចេញនូវការក្តៅក្រហាយ ហើយការចុកចាប់ក្តៅក្រហាយទាំងនេះ វាក្លាយទៅជាទំលាប់ ឬជារបស់ញៀនទៅហើយ ព្រោះថា គ្រាប់ព្រួញពិស គឺកិលេស តណ្ហា ឧបាទាននោះ បានមុតជាប់ទ្រូងរបស់គេតាំងតែពីកើតមកម្ល៉េះ ។ ម្យ៉ាងទៀត គ្រឿងរុំព័ទ្ធ គ្រឿងចងទាំងឡាយ មានការលោភ ការស្រឡាញ់ ការស្អប់ ការចងកំហឹង ការច្រណែន ការចងគំនុំ

ជាដើម សុទ្ធតែជាគ្រឿងចងរុំព័ទ្ធរឹតរួតចិត្តរបស់សត្វទាំងឡាយ មិនឱ្យមើលឃើញថា អ្វីទៅជានរក ថែមទាំងវេចខ្ចប់វិញ្ញាណរបស់សត្វមិនឱ្យរកមធ្យោបាយដ៏សមរម្យសម្រាប់ដោះស្រាយបានឡើយ ។ ព្រោះតែហេតុនេះហើយទើបព្រះអង្គទ្រង់ត្រាស់សំដែងតបអជិតៈថា

លោកត្រូវអវិជ្ជាបិទបាំង លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ជាដើម ។ អវិជ្ជាគឺ សេចក្តីមិនដឹងទុក្ខ សេចក្តីមិនដឹងក្នុងតណ្ហាជាហេតុនាំឱ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខជាដើម ។ ដូច្នេះថ្វីបើនរកមាននៅក្នុងខ្លួននេះយ៉ាងពិតៗក៏ដោយ ក៏សត្វលោកមើលមិនងាយឃើញឡើយ គឺមើលមិនឃើញព្រោះតែអវិជ្ជាហ្នឹងតែម្តង ។ សូមពិចារណានូវពុទ្ធភាសិតមួយកន្លែងទៀតដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ មិនមាននរកឯណា ដែលមានកំដៅយ៉ាងខ្លាំងក្លាជាងនរកគឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយដែលគេមិនត្រូវការ មិនស្រឡាញ់ មិនចូល

ចិត្តនោះទេ របស់ទាំងអស់នេះហើយគឺជានរកដែលមានកំដៅយ៉ាងខ្លាំងសំបើម ។

ម្នាលភិក្ខុទាំងឡាយ នៅមានទៀតណា៎ នរកដែលខ្លាំងក្លាជាងនេះ គួរឱ្យខ្លាចជាងនេះ គឺបុគ្គលណាដែលមិនដឹងតាមសេចក្ដីពិត មិនដឹងនូវអរិយសច្ចៈ ៤ គេរមែងត្រេកអរក្នុងសង្ខារទាំងឡាយ កាលណាគេមានសេចក្ដីត្រេកអរក្នុងសង្ខារទាំងឡាយ គេរមែងវិលកើត កាលណាមានការកើតក៏រមែងមានការចាស់ការឈឺ ការស្លាប់ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខកាយទុក្ខចិត្ត សេចក្ដីថ្នាំងថ្នាក់ចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្ត គេរួចចាកសេចក្ដីទុក្ខទាំងអស់នេះពុំបានឡើយ ។ ម្នាលភិក្ខុទាំងឡាយនេះហើយនរកដែលយើងថាក្ដៅណាស់គួរឱ្យខ្លាចណាស់ ។

សូមកុំភ្លេចថា នរកទាំងអស់មានតែនៅក្នុងអន្ធបុថុជ្ជនដែលជាបុគ្គលជ្រប់ងប់លិចលង់នៅក្នុងកាមគុណទាំងឡាយ ហើយដែលជាមិច្ឆាទិដ្ឋិប៉ុណ្ណោះ ចំណែកព្រះអរិយបុគ្គលទាំងឡាយ មានសោតាបន្នបុគ្គលជាដើម ថ្វីបើលោកនៅមានភាគៈក៏ពិតមែន ប៉ុន្តែលោកលែងធ្លាក់នរកទៀតហើយ ព្រោះចិត្តរបស់លោកបានធ្លាក់

ចុះក្នុងផ្ចិតនៃធមិហើយ ជម្រៅនៃចិត្តរបស់លោក ក៏បានសម្បយុត្តទៅដោយបាមោជ្ជៈហើយ ។

## ✵ ១៣៩ ✵

# បញ្ហានរកបរលោក

ការដែលបរិយាយមកទាំងប៉ុន្មានខាងដើម ភាគច្រើនគឺវិនិច្ឆ័យឱ្យឃើញថា នរកមាននៅក្នុងលោកនេះឯង ។ លំដាប់តទៅនឹងស្តីអំពីនរកបរលោក ថាតើមានមែនឬទេ ? សេចក្តីនេះខ្ញុំក៏មិនបង្ខំមិត្តអ្នកអានទាំងឡាយ ថាត្រូវតែជឿនោះទេ ព្រោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏ទ្រង់ត្រាស់សំដែងក្នុងកាលាមសូត្រថា អ្នកទាំងឡាយកុំទាន់អាលជឿលើក្បួនតម្រា អ្នកទាំងឡាយកុំទាន់អាលជឿលើអ្វីដែលគ្រាន់តែបានឮមក អ្នកទាំងឡាយកុំទាន់អាលជឿថានេះជាសមណៈ នេះជាគ្រូរបស់អ្នកជាដើម ។

ពាក្យថា កុំទាន់អាលជឿ មិនមែនបានន័យថា " មិនឱ្យជឿ " នោះទេ ដោយព្រះអង្គទ្រង់បញ្ជាក់ហេតុផលច្បាស់លាស់ថា "បើអ្នកទាំងឡាយពិចារណាដោយបញ្ញាឃើញច្បាស់ថា ពាក្យ

នេះប្រព្រឹត្តទៅដើម្បី សេចក្តីទុក្ខ មិនមែនជាប្រយោជន៍ អ្នកទាំងឡាយ គប្បីលះបង់ចោលចេញ( តែបើពាក្យនេះប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចំរើន ដើម្បីជាប្រយោជន៍ អ្នកទាំង-ឡាយគប្បី សមាទានយក គប្បីប្រព្រឹត្តជឿតាម) ។

កាលបើនិយាយអំពីនរកបរលោកនោះ មានមនុស្សតិចណាស់ដែលយកចិត្តទុកដាក់ស្តាប់ ព្រោះសេចក្តីទុក្ខក្នុងនរកវាធ្ងន់ហួសវិស័យមនុស្សធម្មតានឹកស្មាន ម្យ៉ាងទៀត ហេតុតែសត្វលោកមិនងាយជឿ ព្រោះតែគេមិនបានឃើញផ្ទាល់ភ្នែកនោះឯង ។

សូមយកបញ្ហាមកពិចារណាបន្តិចមើលថា សម័យ ប៉ុលពតទើបតែកន្លងជាង ២០ ឆ្នាំប៉ុណ្ណោះ មនុស្សដែលមានអាយុ ៣០ ឬ៤០ឆ្នាំឡើងទៅទើបដឹងថា តើសេចក្តីឈឺចាប់ព្រោះអត់អាហារ ព្រោះការធ្វើទារុណកម្ម ព្រោះការកាប់សម្លាប់យ៉ាងណាៗនោះ តែបើយើងលើកយករឿងសម័យនោះមកនិយាយប្រាប់មនុស្សសម័យថ្មីថា ក្នុងសម័យនោះអង្ករមួយកំប៉ុងអាចបបរចែកគ្នាបាន ៤០ឬ៥០ នាក់ឯណោះ មនុស្សសម័យថ្មីនេះ មានគ្នាតិចណាស់ដែលជឿរឿងនោះ គឺមិនជឿទាល់តែសោះថា មនុស្ស ៤០ ឬ៥០ នាក់ អាចរស់បានដោយអង្ករ១កំប៉ុងក្នុង ១ ពេល ហើយថែម

ទាំងធ្វើការធ្ងន់ទៀតផង។ ម្យ៉ាងទៀត មនុស្សខ្វាក់ពីកំណើត រមែងមិនធ្លាប់ស្គាល់ថា អ្វីទៅជាពណ៌ខៀវ ឬពណ៌ស ឬពណ៌លឿងនោះ បើទុកជាយើងខំព្យាយាមពន្យល់ថា ពណ៌នេះពណ៌នោះក្រហមឬសយ៉ាងណាក៏ដោយ ក៏មនុស្សខ្វាក់ពីកំណើតនោះមិនងាយយល់បានឡើយ ហើយថែមទាំងបដិសេធថា ក្នុងលោកនេះគ្មានពណ៌ស ពណ៌ក្រហមអ្វីឡើយ ។

មិត្តអ្នកអានទាំងឡាយ! កាលដែលមនុស្សខ្វាក់ពីកំ-ណើតប្រកែកបដិសេធថា ក្នុងលោកនេះវាគ្មានពណ៌ខៀវ ពណ៌ក្រហមជាដើម តើគួរដែរឬទេ ? សេចក្ដីនេះយ៉ាងណា ឯសត្វលោកភាគច្រើនក៏ខ្វាក់ដូចគ្នាដែរ ព្រោះថាធូលីដ៏ក្រាស់គឺរាគា-ទិកិលេសជាដើម បានហើរចូលទៅកំទេចភ្នែក គឺបញ្ញារបស់សត្វលោកឱ្យខ្វាក់តាំងពីកំណើតមកម្ល៉េះ គេមិនងាយមើលឃើញថា អ្វីទៅជាបាប អ្វីទៅជាបុណ្យ អ្វីទៅជាសួគ៌ ឬ នរកបានទេ គេថែមទាំងបដិសេធថាក្នុងលោកនេះគ្មានបាប គ្មានបុណ្យ គ្មានសួគ៌ គ្មាននរក ក៏យ៉ាងនោះដែរ ។ កាលបើភ្នែកគឺបញ្ញាត្រូវធូលីគឺកិលេស កំទេចអស់យ៉ាងនេះហើយ បើទុកជាយកវ៉ែនតាម៉ាញ៉ូប មកពាក់ត្រួតគ្នាពីរឬបីក៏មិនអាចមើលឃើញឋាននរក

បានឡើយ ។ ប៉ុន្តែចំពោះព្រះអរហន្តទាំងឡាយ ភ្នែកគឺបញ្ញារបស់លោកស្អាតបរិសុទ្ធ ប្រាសចាកធូលី គឺកិលេសហើយៗលោកប្រកបព្រមដោយ វិជ្ជានិងចរណៈជ្រាបច្បាស់នូវលោកនេះនិងលោកខាងមុខ ដូច្នេះ រឿងណាដែលបុថុជ្ជនមិនដឹង ព្រះអរហន្តទាំងឡាយលោកដឹង អ្វីដែលបុថុជ្ជនមើលមិនឃើញ ព្រះអរហន្តទាំងឡាយលោកមើលឃើញ ប្រៀបដូចជារបស់ណាដែលមនុស្សខ្វាក់ពីកំណើតមើលមិនឃើញ តែរបស់នោះមនុស្សដែលមានភ្នែកភ្លឺអាចមើលឃើញក៏ដូច្នោះដែរ ។

# តើបាបនិងបុណ្យនៅត្រង់ណា ?

៩១៧៩

បញ្ហាបាបនិងបុណ្យនេះ ក៏ជាបញ្ហាមួយមានអាថ៌កំបាំងណាស់ដែរ ព្រោះជាវត្ថុម្យ៉ាងដែលយើងមិនអាចនឹងចាប់យកមកបង្ហាញអ្នកដទៃឱ្យមើលឃើញបាន ។ ម្យ៉ាងទៀតសត្វលោករឹងរិតតែលែងមានជំនឿ ព្រោះគេច្រើនតែវាយតំលៃទៅលើអ្វីដែលគេមើលឃើញនឹងភ្នែក ស្តាប់ឮនឹងត្រចៀករបស់គេ ដូចជាមនុស្សល្អខ្លះ បែរជាលំបាកតោកយ៉ាក ចំណែកមនុស្សអាក្រក់ខ្លះ បែរជា

សប្បាយរីករាយ មានអាយុវែងក៏មាន ។ សេចក្តីនេះគួរឱ្យសង្ស័យដែរ តែសូមមិត្តអ្នកអានពិចារណានូវការប្រៀបធៀបដូចតទៅ :

ធម្មតាឪពុកម្តាយកាលបើចិញ្ចឹមកូនឱ្យរស់រានមានជីវិតហើយ រមែងនៅមាន មេត្តា ករុណា ទៅលើកូន ចង់អោយកូនមានចំណេះវិជ្ជាខ្ពង់ខ្ពស់នឹងគេ ក៏បញ្ជូនកូនឱ្យទៅសិក្សាតាំងពីថ្នាក់ទាបរហូតដល់ថ្នាក់ខ្ពស់ ។ ពេលដែលកូននោះបញ្ចប់ការសិក្សាហើយ តើកូននោះអាចចាប់ចំណេះវិជ្ជាមកបង្ហាញឪពុកម្តាយបានដែរឬទេ ? ពិតជាមិនបានឡើយ ប៉ុន្តែយើងអាចដឹងបានយ៉ាងច្បាស់ថា កូននោះពិតជាមានចំណេះវិជ្ជាដោយសំគាល់ទៅលើអាកប្បកិរិយា ការនិយាយស្តីនឹងការសរសេរជាដើម យ៉ាងណាមិញបាបឬបុណ្យដែលបុគ្គលប្រព្រឹត្តហើយ បើទោះជាមិនអាចចាប់យកមកបង្ហាញបានក៏មិនមែនបានន័យថា វាមិនមានឡើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា :

ធម៌[១] ទាំងឡាយមានចិត្តជាប្រធាន មានចិត្តជាធំ បើ

---

(១) សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា យមកវគ្គ

ចិត្តអាក្រក់ហើយ កាយក្តី វាចាក្តី ក៏ប្រព្រឹត្តទៅតាមអំណាចនៃចិត្តបាបនោះ ហើយបាបនោះរមែងជាប់តាមបុគ្គលបាបនោះជានិច្ច ប្រៀបដូចជាកង់រថដែលតែងតែវិលតាមជើងគោដូច្នោះឯង ម្យ៉ាងទៀត បើចិត្តគិតល្អហើយ កាយក្តី វាចាក្តី រមែងប្រព្រឹត្តទៅតាមអំណាចនៃចិត្តល្អនោះ ហើយបុណ្យក៏រមែងអន្ទោលតាមបុគ្គលនោះ ប្រៀបដូចជាស្រមោលអន្ទោលតាមប្រាណដូច្នោះឯង ។

យោងទៅតាមពុទ្ធភាសិតខាងលើ យើងក៏អាចយល់បានថា បុណ្យនិងបាបពិតជាមាន គ្រាន់តែថាខ្សែបុណ្យនិងខ្សែបាបនោះ មិនបានស្ថិតនៅនឹងដដែលៗតែមួយកន្លែងនោះទេ គឺតែងប្រព្រឹត្តទៅ ហូរទៅរឿយៗជានិច្ច តាមពេលតាមសម័យដែលសត្វបានធ្វើនោះឯង យើងមិនអាចចង្អុលបង្ហាញថា បាបនិងបុណ្យស្ថិតនៅត្រង់នេះត្រង់នោះ ឱ្យឃើញនឹងភ្នែកបានឡើយ សេចក្តីនេះឧបមាដូចជារុក្ខជាតិមានផ្លែទាំងឡាយ កាលដែលផ្កានិងក្តិបមិនទាន់ចេញមកខាងក្រៅ យើងក៏មិនអាចចង្អុលប្រាប់អ្នកដទៃឱ្យឃើញថា ផ្លែរបស់វាស្ថិតនៅត្រង់មែក ឬត្រង់ដើមបានឡើយ។ លុះត្រាតែរុក្ខជាតិទាំងនោះបញ្ចេញផ្កានិងក្តិបចេញមក ទើបយើង

អាចមើលឃើញច្បាស់ថា នោះហ្ន៎! ឈើបញ្ចេញផ្លែមកហើយតើ! ន័យនេះ មានសេចក្តីស៊ីគ្នាទៅនឹងពុទ្ធភាសិតមួយកន្លែងទៀតថា :

(១) បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ(បាបោ) បាបានិ បស្សតិ ។
ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ(ភទ្រោ) ភទ្រានិ បស្សតិ ។

*ប្រែថា* : មនុស្សបាបដរាបណាបើបាបមិនទាន់ឱ្យផលទេ ដរាបនោះមនុស្សបាបឃើញអំពើអាក្រក់ថាល្អ លុះតែកាលណាបាបឱ្យផល កាលនោះមនុស្សបាប ទើបឃើញអំពើអាក្រក់ថាអាក្រក់ពិតមែន ។

ដរាបណា អំពើល្អមិនទាន់ឱ្យផល ដរាបនោះមនុស្សល្អរមែងឃើញអំពើល្អថាអាក្រក់ លុះតែកាលណាអំពើល្អឱ្យផល កាលនោះមនុស្សល្អទើបឃើញអំពើល្អ ថាល្អពិតមែន ។

(១) សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា បាបវគ្គ

# រឿងចុន្ទសូករិកៈ

*១៧៩*

ដើម្បីឱ្យជាក់ច្បាស់ថា "តើនរកមានដែរឬទេ ?" នោះ ខ្ញុំនឹងសង្ខេបរឿងមួយដែលមានសំដែងក្នុងគម្ពីរធម្មបទ ដើម្បីឱ្យញាតិញោមបងប្អូនប្រុសស្រីបានអាន ហើយពិចារណាដោយឧបាយនៃប្រាជ្ញាចុះ ។

ចុន្ទសូករិកៈនោះ ជាអ្នកសម្លាប់តែសត្វជ្រូកយកសាច់លក់ដើម្បីចិញ្ចឹមជីវិតពេញ ៥៥ ឆ្នាំ ។ កាលដែលគាត់សម្លាប់ម្តងៗ គាត់ចាប់ជ្រូកចងជើង រួចយកកំណាត់ឈើទៅដាក់ក្នុងមាត់ជ្រូក ដើម្បីឱ្យមាត់វាហារ បន្ទាប់មកគាត់ក៏យកទឹកក្តៅកំពុងពុះទៅចាក់ច្រកក្នុងមាត់សត្វជ្រូកទាំងអស់នោះ។ ទឹកក្តៅបានហូរចូលតាមមាត់ជ្រូក ហូរនាំយកអាហារចាស់អាហារថ្មី និងលាមកចេញមកតាមគូថទាំងអស់។ សត្វជ្រូកទាំងនោះក៏ដល់នូវទុក្ខវេទនាខ្លាំងខ្លោចផ្សា ហើយក៏ស្លាប់ទៅ ។ លុះជ្រូកនោះស្លាប់ហើយគាត់ក៏យកដំបង ៤ ជ្រុងទៅវាយដំឱ្យសាច់ជ្រូកទាំងនោះណែន ដើម្បីមានទម្ងន់ធ្ងន់ និងលក់បានថ្លៃ។ ដល់សម័យគាត់មានជម្ងឺ អំពើដែលគាត់ប្រព្រឹត្តនោះ ក៏បណ្តាលឱ្យភ្លើងអំពីអវីចិមហានរកឆេះ

ឡើងមក ដុតរោលគាត់ឱ្យក្តៅអន្ទះអន្ទែងស្ទុះបម្រះនទៀលឆ្វេឆ្វាវាវទៅមកដោយក្បាលជង្គង់ ហើយស្រែកយំមានសំលេងដូចសំរែកជ្រូកដែលគាត់សម្លាប់ដែរ ។ គាត់រងទុក្ខវេទនាយ៉ាងនេះអស់ ៧ ថ្ងៃ ទើបស្លាប់ៗហើយក៏ទៅកើតក្នុងអវីចីមហានរក ។

✵ ៚ ✵

# ឧបមាទុក្ខក្នុងនរក

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (១) បុគ្គលពាលដែលប្រព្រឹត្តនូវអំពើទុច្ចរិតដោយកាយ ដោយវាចា ដោយចិត្ត លុះបែកធ្លាយរូបកាយស្លាប់ទៅ រមែងកើតក្នុងអបាយទុគ្គតិ វិនិបាតនរក ។

ម្នាលភិក្ខុទាំងឡាយ អ្វីដែលអ្នកផងមិនគួរប្រាថ្នា មិនគួរត្រេកអរ មិនគួរពេញចិត្តនោះគឺនរក ។

---

(១) សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក អដ្ឋមភាគ សុញ្ញតវគ្គ ពាលបណ្ឌិតសូត្រ

ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមិនងាយនឹងធ្វើឧបមាឱ្យដល់គិរិតនរកដែលមានទុក្ខបានឡើយ ។

កាលបើព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូបក្រាបបង្គំទូលសួរសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះអង្គអាចនឹងធ្វើសេចក្ដីឧបមាបានឬទេ ? ព្រះមានព្រះភាគតបថា ម្នាលភិក្ខុតថាគតនឹងអាចធ្វើបាន រួចទ្រង់សំដែងថា:

ម្នាលភិក្ខុទាំងឡាយ ដូចពួករាជបុរសចាប់ចោរប្រព្រឹត្តអាក្រក់បានហើយនាំមកថ្វាយព្រះរាជារួចទូលថា បពិត្រព្រះសម្មតិទេព អ្នកនេះជាចោរ ប្រព្រឹត្តអាក្រក់នឹងព្រះអង្គ បើទ្រង់សព្វព្រះរាជហឫទ័យនិងដាក់អាជ្ញាណាដល់ចោរនោះ សូមទ្រង់ដាក់អាជ្ញានោះចុះ ។

ព្រះរាជាមានរាជឱង្ការថា នៃប្រស្នែងចូរអ្នករាល់គ្នាទៅយកលំពែងមួយរយចាក់បុរសនោះ ក្នុងវេលាព្រឹកព្រហាម ។ ពេលថ្ងៃត្រង់បើបុរសនោះមិនទាន់ស្លាប់ទេ ចូរចាក់មួយរយលំពែងទៀត ។ លុះពេលរសៀលបើបុរសនោះនៅតែមិនស្លាប់ ចូរអ្នករាល់គ្នាយកលំពែងមួយរយទៅចាក់បុរសនោះទៀត ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច ? បុរសនោះកាលបើគេចាក់ដោយលំពែងបីរយ តើនឹងទទួលរងទុក្ខទោមនស្សព្រោះលំពែងនោះជាហេតុដែរឬទេ ?

ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន បុរសនោះសូម្បីគេចាក់ដោយលំពែងតែមួយក៏ទទួលទុក្ខទោមនស្ស ព្រោះលំពែងនោះជាហេតុទៅហើយ ចាំបាច់និយាយថ្វីដល់ទៅចាក់ដោយលំពែងបីរយ ។

គ្រានោះឯងព្រះមានព្រះភាគ ទ្រង់ចាប់យកនូវដុំថ្មតូចមួយប្រមាណប៉ុនបាតដៃហើយត្រាស់សួរភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច ?

ដុំថ្មប្រមាណប៉ុនបាតដៃ ដែលតថាគតកំពុងកាន់នេះនិងស្តេចភ្នំហិមពាន្ត ណាធំជាង ?

ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ដុំថ្មប្រមាណប៉ុនបាតដៃដែលព្រះអង្គកំពុងកាន់នេះតូចពេកណាស់ ប្រៀបផ្ទឹមនឹងស្តេចភ្នំហិមពាន្តនោះមិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយសេចក្ដីនេះ មានឧបមេយ្យដូចបុរសដែលគេចាក់ដោយលំពែងបីរយ រមែងរង ទុក្ខទោមនស្សណាព្រោះលំពែងនោះជាហេតុ ។

ទុក្ខនោះឯង ប្រៀបផ្ទឹមនឹងទុក្ខរបស់នរកក៏មិនដល់នូវការ រាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ,។

# រឿងព្រះមាល័យ

ព្រះមាល័យ ជាអង្គព្រះអរហន្តមានមហិទ្ធិឫទ្ធិប្រហាក់ប្រហែលនឹងព្រះមោគ្គល្លាន ។ ថ្ងៃមួយព្រះមាល័យប្រាថ្នាចុះទៅឋាន នរក ផ្កាឈូកដុះឡើងប៉ុនកង់រទេះទទួលលោក ហើយលោក អធិដ្ឋានដោយឫទ្ធិក៏អណ្ដែតចុះទៅដល់ឋាននរក ពេលបានឃើញ សត្វនរកកំពុងរងទុក្ខសែនមហាខ្លោចផ្សា ទើបលោកប្រើថាមពល បាដិហារ្យសំដែងឫទ្ធិ ធ្វើឱ្យកើតជាភ្លៀងរលត់ភ្លើងនរកគ្រប់

កន្លែងឱ្យត្រជាក់ស្រួល ធ្វើខ្ទះទង់ដែងឱ្យបែកខ្ទាត់ខ្ទាយ ធ្វើភ្នំភ្លើងឱ្យរលាយ ធ្វើរការដែកឱ្យបាក់ខ្ទេចខ្ទី ធ្វើទឹកស្ទឹងប្រៃឱ្យផ្អែមជាដើម ។ ពួកសត្វនរកមានចិត្តសប្បាយរីករាយជាខ្លាំងដោយធូរស្បើយអំពីសេចក្តីទុក្ខដ៏សែនខ្លោចផ្សា បាននាំគ្នាក្រឡេកទៅមើលឃើញព្រះមាល័យ ក៏ចូលទៅកុះករ លើកដៃប្រណម្យថ្វាយបង្គំរួចទូលសួរថា ព្រះតេជគុណនិមន្តមកអំពីណា ? ។ ព្រះមាល័យតបថាៈ អាត្មាមកពីជម្ពូទ្វីបជាទីនៅនៃមនុស្សលោក ។ សត្វនរកនិយាយទាំងយំស្រែកថា បពិត្រព្រះគុណម្ចាស់ យើងខ្ញុំឃើញលោកម្ចាស់ជាលាភធំដុំណាស់ ចាត់ជាទស្សនានុត្តរិយៈយ៉ាងប្រសើរ ។

កាលពីថ្ងៃមុន ព្រះមហាមោគ្គល្លានបាននិមន្តមកប្រោសពួកយើងខ្ញុំឱ្យសេចក្តីសុខសប្បាយយ៉ាងអស្ចារ្យម្តងរួចមកហើយ ឥឡូវបានព្រះតេជគុណនិមន្តមកប្រោសពួកយើងខ្ញុំជាលើកទី ២ ជាភ័ព្វព្រេងល្អណាស់ សូមអង្វរព្រះតេជគុណមេត្តានិមន្តយាងស្តេចយមរាជឱ្យឃាត់ពួក នាយនិរយបាលកុំឱ្យធ្វើបាបពួកយើងពេក ។ ម្យ៉ាងទៀត ពេលលោកម្ចាស់ត្រឡប់ទៅជម្ពូទ្វីបវិញ សូមផ្តាំញាតិមិត្តរបស់យើងខ្ញុំ ឱ្យពួកគេខំប្រឹងប្រែងធ្វើបុណ្យ

កុសល និងឧទ្ទិសកុសលកម្មឱ្យពួកយើងខ្ញុំផង ហើយសូមព្រះតេជគុណជួយហាមប្រាមដល់ពួកញាតិរបស់យើងខ្ញុំផង កុំឱ្យពួកគេធ្វើអំពើអាក្រក់ឱ្យសោះ ហេតុដែលនាំឱ្យពួកយើងធ្លាក់មកកាន់នរកសោយទុក្ខធ្ងន់សម្បើមអស្ចារ្យយ៉ាងនេះ ព្រោះកាលនៅជាមនុស្សយើងបានប្រព្រឹត្តអំពើអាក្រក់ទាំងឡាយ ច្រើនប្រការ មានការសំលាប់សត្វជាដើម ។

ព្រះមាល័យបានស្តាប់ពាក្យអង្វររបស់សត្វនរកដូច្នេះ ហើយក៏មានព្រះទ័យករុណាកើតឡើង ទើបចូលឈានមានអភិ-ញ្ញាជាទីតាំងហោះសំដៅទៅរកស្តេចយមរាជ បានដល់ប្រាសាទយ៉ាងលឿនប្រហែលផ្ទាត់ម្រាមដៃម្តង ។

គ្រានោះអាមាត្យឈ្មោះ សិរិគុត្ត អ្នកយាមទ្វារ ដឹងអធ្យាស្រ័យរបស់ព្រះថេរៈ ហើយក៏ចូលទៅក្រាបទូលដំណឹងដល់ស្តេចយមរាជៗ បានទ្រង់រាជានុញ្ញាតិឱ្យព្រះថេរៈចូលមកជួបដោយសិរី ។ ព្រះថេរៈនិមន្តចូលទៅក្នុងប្រាសាទបានគង់លើអាស-នៈដ៏សមគួរ ហើយស្តេចយមរាជព្រមទាំងបរិវារក៏ក្រាបបង្គំដោយគោរព រួចត្រាស់សួរថា : **កុតោ អាគច្ឆថ ភន្តេ** បពិត្រព្រះ

គុណម្ចាស់ដ៏ចំរើន តើព្រះគុណម្ចាស់និមន្តមកពីទីណាហ្នំ ? ចង់ជួប និងញោម តើមានថេរកិច្ចយ៉ាងណាខ្លះ ?

ព្រះមាល័យថ្វាយព្រះពរថា អាត្មាភាពធ្វើដំណើរមកពី ជម្ពូទ្វីប ប្រាថ្នាមកជួបនឹងព្រះអង្គ ។

*យមរាជ* : ព្រះតេជគុណម្ចាស់ព្រះនាមអ្វី ?

*មាល័យ* : អាត្មាភាពព្រះនាមមាល័យទេវថេរៈ។

*យមរាជ* : ញោមសង្ស័យណាស់ព្រះនាមរបស់ព្រះគុណ ម្ចាស់វែងអ្វីម្ល៉េះ ? តើបានសេចក្តីថាដូចម្តេចទៅ ?

*មាល័យ* : ថ្វាយព្រះពរ បើស្តេចមានប្រាថ្នាចង់ជ្រាបអំពី សេចក្តីនៃនាមរបស់អាត្មាភាព១ នឹងថ្វាយសេចក្តីបាន។ ដែល ឈ្មោះថា "មាល័យ"ព្រោះអាត្មាភាពតែងគង់នៅក្នុងកោះមាល័យ ដែលមានដើមខ្លឹមចន្ទន៏ក្រហមច្រើន បានជាអ្នកផងទាំងពួងហៅ អាត្មាថា "មាល័យ"ដូច្នេះ ជាប់ជាហូរហែមក ។ ពាក្យថា ទេវៈ ពី ព្រោះអាត្មាភាពជាវិសុទ្ធិទេពដ៏ប្រសើរជាងទេព្តានិងមនុស្សទាំង-ឡាយ។ ពាក្យថា"ថេរៈ"ពីព្រោះអាត្មាភាពជាអ្នកមាំមួនខ្ជាប់ខ្ជួន ដោយសីល សមាធិ បញ្ញា ។ រួមពាក្យថា: មាល័យ ទេវថេរៈ

បានសេចក្ដីថា : ព្រះមាល័យជាវិសុទ្ធិទេពខ្ជាប់ខ្ជួនដោយសីល សមាធិ បញ្ញា ។

*យមរាជ* : តាមដែលព្រះគុណវិសជ្ជនាមកនេះ ញោមស្ដាប់យល់ចូលចិត្តហើយ ប៉ុន្តែតើព្រះគុណម្ចាស់និមន្តមកនេះមានកិច្ច-ការអ្វី ?

*មាល័យ* : អាត្មាភាពធ្វើដំណើរមកកាន់សំណាក់របស់ព្រះ-អង្គក្នុងថ្ងៃនេះមានបំណងចង់សន្ទនាសាកច្ឆាការពិតថា: បណ្ដាសត្វនរកទាំងឡាយដែលបានរងទុក្ខវេទនារួចហើយ និងកំពុងរងទុក្ខព្រមទាំងបំរុងនឹងមករងទុក្ខក្នុងសំណាក់របស់ព្រះអង្គជាបន្តបន្ទាប់គ្នានេះ តើអំពើគ្រប់បែបយ៉ាងព្រះអង្គជាអ្នកបង្គាប់បញ្ជាឬ ? ឬមួយនាយ និរយបាលធ្វើដោយចិត្តឯងទៅទេ ?

*យមរាជ* : ញោមមិនបានចេញពាក្យបង្គាប់ដោយខ្លួនឯងទេ ។

*មាល័យ* : បើដូច្នេះទេ តើអ្នកណាជាអ្នកបង្គាប់បញ្ជាទៅ ?

*យមរាជ* :អំពើដែលសត្វលោកកាលនៅជាមនុស្សធ្វើដោយ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហ្នឹងហើយ ដែលបណ្ដាលឱ្យធ្លាក់មកទទួលផលបាបរបស់ខ្លួនយ៉ាងនេះ ។

*មាល័យ* ៖ ស្ដេចត្រាស់ថា មិនបានបង្គាប់ទេ គឺផលកម្ម ជាអ្នកបង្គាប់ អាត្មាភាពចូលចិត្តហើយ ប៉ុន្តែគួរដែរឬ? បើព្រះ-អង្គគង់នៅស្ងៀម កន្ទឹមកន្ទើយ មិនរវល់ មិនហាមប្រាមនាយនិរយបាល ឱ្យបន្ធូរបន្ថយបន្ធើរដៃខ្លះផង បណ្ដោយឱ្យធ្វើបាបគេទទេៗយ៉ាងនេះមិនសំណំសំនួនទាល់តែសោះ ។

*យមរាជ* ៖ ឰយ៉ា ! ព្រះមាល័យកិនញោមដូចជាគេកិនអង្ករហើយតើ ! រឿងនេះសូមពិតថា ញោមបន្ធូរបន្ថយមិនបានជាដាច់ខាត ។ ពីព្រោះញោមមិនមែនជាម្ចាស់បាបកម្មរបស់សត្វនរកទាំងនោះឯណា សត្វណាធ្វើបាបច្រើនក៏ត្រូវមកទទួលទោសធ្ងន់ សត្វណាធ្វើបាបតិចក៏ត្រូវទទួលទោសស្រាល ។ បើព្រះគុណម្ចាស់ចង់ជ្រាប ចាំញោមពិតឱ្យជ្រាបថា មនុស្សមានបាប កាលបើដល់ពេលស្លាប់ ត្រូវចុះមកកាន់ឋាននរកតាមកម្មរបស់ខ្លួននាំមកពួកនាយនិរយបាលបានបណ្ដើរមកឱ្យញោមៗ ឃើញហើយក៏មានចិត្តអាណិតស្ទើរបែកប្រមាត់ ។ កាលនាយនិរយបាលសូត្របញ្ជីទោសអាក្រក់ឱ្យស្ដាប់ហើយ ញោមរឹតតែអាសូរឡើង រួចញោមក៏បានសួរនូវទេវទូតទាំងឡាយ៥ប្រការក្នុងទីចំពោះមុខសត្វនោះ ដើម្បីឱ្យសត្វទាំងឡាយនោះអានស្មារតីឆ្លើយរួចនូវបញ្ហាណាមួយ

ញោមនឹងលើកលែងទោសឱ្យឡើងទៅកាន់ឋានសួគ៌បាន ។ ប៉ុន្តែ ពុំងាយមានឃើញសត្វណាមួយឆ្លើយរួចសោះ ថែមទាំងពោលពាក្យទ្រគោះបោះបោកមកលើញោមទៀតផង។ ញោមទ័លគំនិតក៏បង្គាប់ឱ្យនាយនិរយបាលនាំខ្លួនទៅទម្លាក់ក្នុងរណ្ដៅនរក ឱ្យសោយទុក្ខតាមកម្មរបស់ខ្លួន ដើម្បីឱ្យរាងចាល ។

*មាល័យ* : យីអើ! មកពីនោះមកដល់នេះ គឺសង្ខាតមកសួរការទេតើ បើមិនកិនធ្វើម្ដេចនឹងបានអង្ករ បើមិនសួរធ្វើម៉េចនឹងបានដឹងខុសត្រូវ ។ តើមហាបពិត្រសួរនូវទេវទូតនោះយ៉ាងដូចម្ដេចទៅ ? ទេវទូតទាំង ៥ ប្រការនោះ គឺអ្វីខ្លះទៅ ?

*យមរាជ* :បពិត្រព្រះគុណម្ចាស់ !បន្ទាប់ពីនាយនិរយបាលបានអានបញ្ជីទោសកំហុសរបស់សត្វនោះហើយ ញោមក៏សួរទេវ-ទូតទាំង ៥ ប្រការដោយសំដីទន់ភ្លន់ ផ្អែមល្ហែមថា :

### ទេវទូតទី ១ (១)

*យមរាជ* = "អម្ភោ ន ត្វំ អទ្ទស មនុស្សេសុ បឋមំ ទេវទូតំ បាតុភូតន្តិ " ម្នាលបុរសដ៏ចំរើន អ្នកឯងមិនបានឃើញនូវទេវទូតទី ១ ដែលកើតប្រាកដក្នុងមនុស្ស លោកទេឬ ?

(១) មជ្ឈិមនិកាយ ឧបរិបណ្ណាសក សុញ្ញតវគ្គ ទេវទូតសូត្រ

*បុរស* = " នាទ្ទសំ ភន្តេតិ " សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។

*យមរាជ* ="អម្ភោ ប្ញុរិស ។ល។ សេមានត្ថិ" ម្នាលបុរស ដ៏ចំរើន អ្នកឯងមិនបានឃើញកូនខ្ចីកំពុងដេកផ្ងារ ដេកត្រាំក្នុងទឹកមូត្រ និង លាមករបស់ខ្លួនក្នុងមនុស្ស លោកទេឬ ?

*បុរស* = "អទ្ទសំ ភន្តេតិ " សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។

*យមរាជ* ="អម្ភោ ប្ញុរិស តស្ស ។ល។ មនសាតិ" ម្នាលបុរសដ៏ចំរើន តាំងតែពីអ្នកធំដឹងក្តីរហូតដល់ខ្លួនចាស់ តើធ្លាប់មានគំនិតថា អាត្មាអញនេះឯង មានជាតិគឺការកើតជាធម្មតា មិនអាចកន្លងនូវជាតិទៅបានឡើយ កាលណាបើអាត្មាអញស្លាប់ទៅនឹងត្រូវត្រឡប់មកកើតដេកនៅប្រឡាក់ដោយទឹកមូត្រនិងលាមករបស់ខ្លួនឯងទៀតមិនខាន បើដូច្នោះគួរតែអាត្មាអញធ្វើនូវអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្តដូច្នេះ ដែរឬ ?

*បុរស* = "នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ " សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាចនឹងគិតឃើញដូច្នោះបាន

ឡើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ (ខ្ញុំព្រះអង្គគិតតែពីការរកស៊ី ចិញ្ចឹមជីវិតតែប៉ុណ្ណោះ) ។

*យមរាជ* ="អម្ភោ បុរិស បមាទតាយ ៗលៗ បដិសំ-
ទេតិស្សសីតិ " ម្នាលបុរសដ៏ចំរើន ព្រោះតែសេចក្ដីប្រមាទ បានជាអ្នកឯងមិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ។ អើបុរស បើអ្នកឯងមានសេចក្ដីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (ទារុណកម្មដល់អ្នកឯង) យ៉ាងនោះ ព្រោះបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឱ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឱ្យទេ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលនូវវិបាកនៃបាបកម្មនោះវិញ ។

# ទេវទូតទី ២

កាលបើបុរសនោះ ឆ្លើយថាខ្លួនមិនបានស្គាល់នូវទេវទូតទី១ ព្រោះហេតុតែខ្លួនជាមនុស្សប្រមាទដូច្នេះហើយ ស្ដេចយមរាជក៏តាំងផ្ដើមសួរដេញដោល សួរឈ្លេចឈ្លីនូវទេវទូតទី២ ទៀតថា :

*យមរាជ* = "អម្ភោ បុរិស ន ត្វំ អទ្ទស មនុ-
ស្សេសុ ទុតិយំ ទេវទូតំ បាតុភូតន្តិ "ម្នាលបុរសដ៏ចំរើន
អ្នកឯងមិនបានឃើញនូវទេវទូតទី២ ដែលកើតប្រាកដក្នុងមនុស្ស
លោកទេឬ ?

*បុរស* = "នាទ្ទសំ ភន្តេតិ " សូមទ្រង់ព្រះមេត្តា
ប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ?

*យមរាជ* = "អម្ភោ បុរិស ។ល។ គិលកាហត-
គត្តន្តិ " នៃបុរសដ៏ចំរើន ចុះអ្នកឯងមិនបានឃើញស្ត្រី ឬបុរស
ដែលមានអាយុ ៨០ឆ្នាំ ៩០ឆ្នាំ ឬ ១០០ឆ្នាំ ដែលចាស់គ្រាំគ្រា
មានឆ្អឹងជំនីរកោងដូចជាបង្កង់ផ្ទះ មានកាយកោងកាន់ឈើច្រត់
ដើរទៅញ័ររន្ធត់ក្តៅអន្ទះសា មានធ្មេញបាក់ មានសក់ស្កូវ មាន
ក្បាលឆក មានក្បាលទំពែក មានស្បែកជ្រីវជ្រួញ មានខ្លួនសៅ
ហ្មងដោយប្រជ្រុយ ក្នុងមនុស្សលោកទេឬ ?

*បុរស* = "អទ្ទសំ ភន្តេតិ ": សូមទ្រង់ព្រះមេត្តា
ប្រោស ខ្ញុំព្រះអង្គបានឃើញ ។

*យមរាជ* ="អម្ភោ បុរិស ។ល។ មនសាតិ" ម្នាល
បុរសដ៏ចំរើន ចាប់តាំងពីអ្នកឯងធំដឹងក្តីរហូតដល់ចាស់ តើអ្នក

ធ្លាប់មានគំនិតថា អាត្មាអញមានសេចក្តីចាស់គ្រាំគ្រាជាធម្មតា មិនអាចគេចវេះអំពីសេចក្តីចាស់គ្រាំគ្រាទៅបានឡើយ បើដូច្នេះ( មុនពេលដែលអាត្មាអញ ក្លាយទៅជាមនុស្សចាស់ជរា) អាត្មាអញគួរតែធ្វើអំពើល្អ ដោយកាយ ដោយវាចា និងដោយចិត្ត (ឱ្យបានច្រើន ) ដូច្នេះដែរឬ ?

*បុរស* = "**នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ**" សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញទេ) សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។

*យមរាជ* ="**អម្ភោ បុរិស បមាទតាយ ។ល។ បដិសំវេទិស្សសីតិ** ": ម្នាលបុរសដ៏ចំរើន ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត។ អើ បុរស បើអ្នកឯងមានសេចក្តីប្រមាទ (ហើយធ្វើនូវអំពើបាបកម្ម) យ៉ាងណា នាយនិរយបាលនឹងធ្វើ( នូវទោសដល់អ្នក) យ៉ាងនោះវិញ ត្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឱ្យទេ ។ល។ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងបានធ្វើដោយខ្លួនឯង អ្នកឯងនឹងត្រូវទទួលនូវវិបាកនៃបាបកម្មនោះវិញ ។

# ទេវទូតទី ៣

ស្តេចយមរាជក៏បន្តសួរដេញដោល សួរឈ្លេចឈ្លីនូវទេវ-ទូតទី ៣ បន្តទៀត ៖

*យមរាជ* = "**អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ តតិយំ ទេវទូតំ បាតុភូតន្តិ**" ៖ ម្នាល បុរសដ៏ចំរើន អ្នកឯងមិនបានឃើញនូវទេវទូតទី ៣ ដែលកើតប្រាកដក្នុងមនុស្សលោក ទេឬ ?

*បុរស* = "**នាទ្ទសំ ភន្តេតិ** "៖ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។

*យមរាជ* = "**អម្ភោ បុរិស ន ត្វំ ។ល។ បុរិសំ វា អាពាធិកំ ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សេមានំ អញ្ញេហិ វុដ្ឋាបិយមានំ អញ្ញេហិ សំវេសិយមានន្តិ**" ៖ នែបុរសដ៏ចំរើន អ្នកឯងមិនធ្លាប់បានឃើញស្ត្រី ឬបុរសដែលមានជំងឺដល់នូវសេចក្តីលំបាក កំពុងដេកត្រាំក្នុងទឹកមូត្រលាមករបស់ខ្លួន( មានការលំបាកយ៉ាកយ៉ាប់ដោយជម្ងឺទាំងឡាយដូចជាគ្រុនក្តៅ គ្រុនចាញ់ រោគថ្លើម រោគខ្យល់ រោគធ្លាក់ឈាមជាដើម ដេកថ្ងូរហ៊ឺះ) លុះតែមានពួកជនដទៃជួយគ្រាហ៍ ទើបក្រោកឡើងរួច ក្នុងមនុស្សលោកដែរឬ ?

*បុរស* = "**អទ្ធសំ ភន្តេតិ** ": សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គធ្លាប់បានឃើញ ។

*យមរាជ* = "**អម្ភោ បុរិស តស្ស ។ល។ មនសាតិ** " : ម្នាលបុរសដ៏ចំរើន តាំងតែពីអ្នកធំដឹងក្ដីរហូតដល់ចាស់ តើធ្លាប់មានគំនិតថា អាត្មាអញនេះមានជម្ងឺជាធម្មតា មិនអាចកន្លងបង់នូវជម្ងឺទៅបានឡើយ បើដូច្នេះ(មុនពេលដែលរោគទាំងឡាយចូលមកយាយីរុករានរូបកាយរបស់អាត្មាអញ) គួរណាស់តែអាត្មាអញធ្វើនូវអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ?

*បុរស* = "**នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ** ": សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច(នឹងគិតឃើញ)ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។

*យមរាជ* = "**អម្ភោ បុរិស បមាទ- វតាយ ។ល។ បដិសំវេទិស្សសីតិ** ": ម្នាលបុរសដ៏ចំរើន ព្រោះតែសេចក្ដីប្រមាទបានជាអ្នកឯង មិនបានធ្វើសេចក្ដីល្អ ដោយកាយ ដោយវាចា ដោយចិត្ត។ អើបុរស បើអ្នកឯងមានសេចក្ដីប្រមាទ

(ប្រព្រឹត្តិធ្វើនូវបាបកម្ម)យ៉ាងណា នាយនិរយបាលនឹងធ្វើ (នូវទោសដល់អ្នក)យ៉ាងនោះវិញ ត្បិតថាបាបកម្មរបស់អ្នកឯងនោះមិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ ។ល។ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ បាបកម្មនុ៎ះគឺអ្នកឯង បានប្រព្រឹត្តធ្វើដោយខ្លួនឯង អ្នកឯងនឹងត្រូវទទួលនូវវិបាកនៃបាបកម្មនេះវិញ ។

# ទេវទូតទី ៤

បន្ទាប់មកស្ដេចយមរាជក៏បន្តសួរ ឈ្លេចឈ្លីនូវទេវទូត ទី៤ជាបន្តទៀតថា :

*យមរាជ* = "**អម្ភោ បុរិស ន ត្វំ អទ្ទសំ មនុស្សេសុ ចតុត្ថំ ទេវទូតំ បាតុភូតន្តិ** ": នែបុរសដ៏ចំរើន តើអ្នកឯងធ្លាប់បានឃើញទេវទូតទី ៤ ដែលប្រាកដក្នុងមនុស្ស លោកទេឬ ?

*បុរស* = "**នាទ្ទសំ ភន្តេតិ**" : សូមទ្រង់ព្រះមេត្តាប្រោសខ្ញុំព្រះអង្គមិនបានឃើញទេ ។

*យមរាជ* = "**អម្ភោ បុរិស ន ត្វំ ។ល។ អទ្ទសន្តេតិ**": ម្នាលបុរសដ៏ចំរើន ចុះអ្នកឯងធ្លាប់បានឃើញនូវព្រះរាជាទាំង-ឡាយ កាលចាប់ចោរដែលប្រព្រឹត្តិអាក្រក់បានហើយ តែងត្រាស់

បង្គាប់ឱ្យគេធ្វើទោសទាំងឡាយច្រើនប្រការដល់ចោរនោះ ដូចជាឱ្យវាយដំច្រំធាក់ ឱ្យកាត់ដៃ កាត់ជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះ ដាក់គុក ដាក់ច្រវាក់ ។ល។ រហូតដល់សម្លាប់ដោយការព្យួរក ឬកាត់កជាដើម ដូច្នេះដែរឬទេ ?

*បុរស* = "អទ្ទសំ ភន្តេតិ" : សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គធ្លាប់បានឃើញ ។

*យមរាជ* = "អម្ភោ បុរិស តស្ស ។ល។ មនសាតិ" នៃបុរសដ៏ចំរើន កាលអ្នកឯងធំដឹងក្តីឡើងរហូតដល់ចាស់ តើធ្លាប់មានគំនិតថា ការប្រព្រឹត្តនូវអំពើលាមក អំពើបាប អំពើអកុសល សូម្បីតែក្នុងបច្ចុប្បន្ននេះ ក៏ត្រូវគេធ្វើទោស ដាក់ទារុណកម្មយ៉ាងនេះទៅហើយ ចាំបាច់និយាយថ្វីដល់ទៅទុក្ខទោសនៅក្នុងបរលោក បើដូច្នេះគួរណាស់តែអាត្មាអញប្រញាប់ប្រញាល់ធ្វើនូវអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ?

*បុរស* = "នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ" សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច(នឹងគិតឃើញ)ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។

*យមរាជ* ="អម្ភោ បុរិស បមាទតាយ ។ល។ បដិសំវេទិស្សសីតិ" = ម្នាលបុរសដ៏ចំរើន ព្រោះតែសេចក្ដីប្រមាទ បានជាអ្នកឯងមិនបានធ្វើនូវអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ។ អើបុរស បើអ្នកឯងមានសេចក្ដីប្រមាទ(ហើយធ្វើនូវអំពើបាប)យ៉ាងណា ពួកនាយនិរយបាលនឹងធ្វើ(ទារុណកម្មដល់អ្នកឯង)យ៉ាងនោះវិញ ត្បិតបាបកម្មរបស់អ្នកឯងមិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ ។ល។ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ ឯបាបកម្មនុះ គឺអ្នកឯងបានធ្វើដោយខ្លួនឯង អ្នកឯងនឹងត្រូវទទួលនូវវិបាកនៃបាបកម្មនោះវិញ ។

## ទេវទូតទី ៥

បុរសនោះ បើទោះបីជាស្ដេចយមរាជសួរដេញដោលតាំងពីទេវទូតទី ១ រហូតដល់ទេវទូតទី ៤ ក៏នៅតែជាអ្នកមិនមានស្មារតីដដែល ព្រោះភារៈនៃខ្លួនជាមនុស្សធ្លាប់មានសេចក្ដីប្រមាទ ប្រកបដោយមិច្ឆាទិដ្ឋិ មិនជឿបុណ្យបាប មិនដឹងគុណទោស ស្ដេចយមរាជក៏ចាប់ផ្ដើម សួរទេវទូត ទី ៥ ជាលើកចុងក្រោយ :

*យមរាជ* = "អម្ភោ បុរិស ន ត្វំ អទ្ទសំ មនុស្សេសុ បញ្ចមំ ទេវទូតំ បាតុភូតន្តិ" = ម្នាលបុរសដ៏ចំរើន អ្នកឯងមិនធ្លាប់ឃើញនូវទេវទូតទី ៥ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ?

*បុរស* = "**នាទ្ទសំ ភន្តេតិ** "សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនធ្លាប់បានឃើញទេ ។

*យមរាជ* = "**អម្ភោ បុរិស ន ត្វំ ។លៗ ឥត្ថិំ វា ជានន្តិ**" = នៃបុរសដ៏កំសត់ តើអ្នកឯងមិនធ្លាប់បានឃើញស្ត្រី ឬបុរសដែលស្លាប់អស់មួយថ្ងៃ ឬស្លាប់អស់ពីរថ្ងៃ ឬស្លាប់អស់បីថ្ងៃ កំពុងហើមប៉ោង មានសម្បុរខៀវ ច្រើនមានខ្ទុះឈាមហូរចេញតាមទ្វារផ្សេងៗឬទេ ?

*បុរស* = "អទ្ទសំ ភន្តេតិ" = សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គធ្លាប់បានឃើញ ។

*យមរាជ* =" អម្ភោ បុរិស តស្ស ។លៗ មន-សាតិ"= ម្នាលបុរសដ៏ចំរើន ចាប់តាំងពីកាលដែលអ្នកឯងធំដឹងក្តីរហូតដល់ចាស់ តើធ្លាប់មានគំនិតថា (ទីបំផុតអាត្មាអញនឹងក្លាយទៅជាសាកសពមានសភាពហើមប៉ោង មានខ្ទុះនិងឈាមហូរចេញតាមទ្វារទាំងឡាយ ដូចជាសាកសពដែលកំពុងប្រាកដក្នុងទីចំពោះមុខ

របស់អាត្មាអញនេះ ដូច្នោះដែរមិនខាន) អាត្មាអញមានសេចក្ដីស្លាប់ជាធម្មតា មិនអាចគេចផុតពីសេចក្ដីស្លាប់បានឡើយ បើដូច្នេះ មុនពេលសេចក្ដីស្លាប់មកដល់អាត្មាអញត្រូវធ្វើអំពើល្អ ជាបុណ្យកុសលដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ?

*បុរស*="នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ"=សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។

*យមរាជ*= "អម្ភោ បុរិស បមាទវតាយ ។ល។ បដិសំវេទិស្សសីតិ " ម្នាលបុរស ព្រោះតែសេចក្ដីប្រមាទ ( មិនស្គាល់នូវទេវទូតទាំងឡាយនោះហើយ ) បានជាអ្នកឯងមិនបានធ្វើនូវអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ។ អើបុរស បើអ្នកឯងមានសេចក្ដីប្រមាទយ៉ាងណា ពួកនាយនិរយបាលនឹងធ្វើទោសដល់អ្នកឯង យ៉ាងនោះវិញ ត្បិតថាបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ ។ល។ មិនមែនជាទេវតាទាំងឡាយធ្វើឱ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងបានធ្វើដោយខ្លួនឯង អ្នកឯងនឹងត្រូវទទួលនូវវិបាកនៃបាបកម្មនោះដោយខ្លួនឯង។

បពិត្រព្រះមាល័យដ៏ចំរើន សូមព្រះគុណម្ចាស់ស្ដាប់មើលចុះ សូម្បីតែញោមសាកសួរដេញដោល សួរឈ្មេចឈ្មើនូវទេវទូត

ជាគម្រប់៥យ៉ាងនេះហើយ សត្វទាំងអស់នោះនៅតែរកគិតដល់បុណ្យកុសលមិនឃើញដដែល ដូចដែលព្រះគុណម្ចាស់ទ្រង់ជ្រាបស្រាប់ហើយ ធម្មតាគ្រូក្តី មាតាបិតាក្តី តែងហាមប្រាមកូនចៅរបស់ខ្លួនមិនឱ្យប្រព្រឹត្តខុសទុកមុនជាញយៗ លុះកូននោះប្រព្រឹត្តកន្លងនូវដំបូន្មានរបស់ខ្លួន គ្រូឬមាតាបិតាតែងចាប់កំហុស ហើយធ្វើទោសដាក់ទណ្ឌកម្ម មានការវាយនិងជេរជាដើម ក៏ព្រោះតែសេចក្តីអាណិតស្រឡាញ់កូន ចង់ឱ្យកូននោះល្អ យ៉ាងណាមិញញោមក៏មានមេត្តាសត្វនរកនោះដូច្នោះដែរ បានសួរនូវទេវទូត៥ដង បញ្ជាក់ជាមុនញយៗ ឱ្យមានស្មារតីភ្ញាក់រលឹកឡើង បើសិនជាសត្វណាឆ្លើយរួចនូវ ខ ណាមួយ ក៏ទុកជាបានការ នឹងឱ្យរួចទោស។ ដល់សួរទៅថា មិនដឹងមិនយល់គ្រប់តែទាំងអស់ដូច្នេះឃើញថាសត្វនេះប្រមាទហើយស្រវឹងពេញទីចំពោះមុខទុក្ខទាំង ៥ ប្រការ មិនសមនឹងឱ្យបានឋានខ្ពស់នៅទេ ព្រោះហេតុដូច្នោះឯងបានជាញោមបង្គាប់ឱ្យនាយនិរយបាល នាំយកទៅទំលាក់ក្នុងរណ្តៅនរកតាមផលកម្មទៅ ។

បើម្លឹងៗ តើព្រះមាល័យយល់ដូចម្តេចដែរ ?តើឱ្យញោមធ្វើដូចម្តេចទៅទៀត ?

ព្រះមាល័យបានសន្ទនាផ្ទាល់ជាមួយស្តេចយមរាជ អស់រយៈពេលយ៉ាងយូរ ក៏ឃើញថា ស្តេចយមរាជមានអធ្យាស្រ័យអនុគ្រោះដល់សត្វនរកល្អដែរ ទើបថ្វាយព្រះពរថា សាធុ! សាធុ! ហើយព្រះមាល័យលាស្តេចយមរាជ ត្រឡប់មកកាន់ឋានមនុស្សវិញ ហើយព្រះមាល័យបាននិមន្តទៅប្រាប់ញាតិមិត្តរបស់សត្វនរកគ្រប់ច្រកល្ហកតាមបណ្តាំរបស់សត្វនរក ។

ពួកប្រជាជនបានឮហើយ មានចិត្តភ័យខ្លាចចំពោះទុក្ខទោសក្នុងនរកជាខ្លាំង ហើយក៏បាននាំគ្នាទំលាក់ចោលនូវបាបគ្រប់បែបយ៉ាង និងនាំគ្នាធ្វើបុណ្យឱ្យទានរក្សាសីល ចំរើនភាវនាប្រមូលផ្តុំប្រជុំកុសល ឧទ្ទិសមគ្គផលទៅដល់នរកប្រេតជាញាតិរបស់ខ្លួន នៅចំពោះព្រះភ័ក្ត្រព្រះមាល័យ ។ ពួកសត្វនរកប្រេតខ្លះដែលមានបាបកម្មស្រាលៗ ក៏បានទទួលនូវការអនុមោទនាបុណ្យកុសល ហើយបានរួចរបូតចាកស្ថាននរកប្រេតទៅទីស្ថានសុខក្សេមក្សាន្តទៅ ។

# សេចក្តីទុក្ខក្នុងនរកបរលោក

ម្នាលភិក្ខុ ទាំងឡាយ ! យមរាជ ក្រោយពេលដែលបានចោទសួរបុរសនោះនូវទេវទូតទាំង ៥ ចប់ហើយ (តែបុរសនោះឆ្លើយមិនរួចសូម្បីមួយ ខ ណាសោះ ស្តេចក៏បានធ្វើនូវតរិយាបថស្ងៀមកន្តើយ ។

ម្នាលភិក្ខុ ទាំងឡាយ ! លំដាប់នោះឯង នាយនិរយបាលទាំងឡាយក៏ធ្វើកម្មករណ៏ឈ្មោះបញ្ចពិធពន្ធន៍ (ចំណង៥ប្រការ) ចំពោះបុរសនោះ គឺផ្តេកបុរសនោះ ហើយបោះដែកគោលក្តៅត្រង់ដៃសងខាងនិងត្រង់ជើងទាំងសងខាង ហើយនិងចំពាក់កណ្តាលទ្រូង ។ បុរសនោះសោយទុក្ខវេទនាខ្លាំងក្លាខ្លោចផ្សា ដរាបណាបាបកម្មមិនទាន់អស់ ក៏ពុំទាន់ស្លាប់ដរាបនោះ ។

ម្នាលភិក្ខុទាំងឡាយ ជួនកាលនាយនិរយបាលចាប់បុរសនោះផ្តេកផ្ងារហើយច្រាសដោយពូថៅ ជួនកាលចាប់ជើងលើកឡើងលើ ដាក់ក្បាលសំយ៉ុងចុះ ហើយពន្លះដោយកាំបិត ជួនកាលទឹមបុរសនោះនឹងរទេះបរទៅមកលើផ្ទៃដែកក្តៅដែលភ្លើងកំពុងឆេះក្រហមច្រាល ជួនកាលប្រើបុរសនោះឱ្យរត់ឡើងរត់ចុះតាមភ្នំ

ធំៗដែលមានភ្លើងកំពុងឆេះសន្ធោសន្ធៅ ជួនកាលចាប់ជើងក្របួច ចោលទៅក្នុងខ្ទះទង់ដែងដែលមានទឹកក្តៅកំពុងតែពុះកញ្ជ្រោល យ៉ាងខ្លាំងក្លា។ សត្វនរកដែលត្រូវស្ងោរក្នុងខ្ទះទង់ដែង មានចល-នាស្ទុះស្ទាដូចពពុះទឹក ជួនកាលអណ្តែតឡើង ជួនកាលលិចចុះ ជាសត្វមានសេចក្តីទុក្ខក្លាខ្លាំងខ្លោចផ្សា បើបាបកម្មមិនទាន់អស់ ដរាបណា ក៏មិនទាន់ស្លាប់ដរាបនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ជួនកាលនាយនិរយបាល ចាប់បុរស នោះបោះចូលទៅក្នុងមហានរក ។ មហានរកមានមុំ៤ មានទ្វារ៤ ខាងក្នុងចែកចេញជាចំណែកតូច ចំណែកធំ មានកំពែងដែកពទ្ធ ជុំវិញ មានគ្របបិទពីលើធ្វើដោយដែក រណ្តៅនៃមហានរកទាំង មូលមានភ្លើងឆេះសន្ធោសន្ធៅសព្វទាំងអស់ គឺអណ្តាតភ្លើងឆាប ឆេះពីជញ្ជាំងខាងកើតដល់ជញ្ជាំងខាងលិច ពីជញ្ជាំងខាងជើង ។ល។ ឆេះពីផ្ទៃខាងលើដល់បាតខាងក្រោម ។

ម្នាលភិក្ខុទាំងឡាយ! ក្នុងសម័យខ្លះ គឺយូរៗមានម្តង ទ្វារ ខាងមុខនៃមហានរកក៏បើកចេញមកបុរសនោះក៏រត់យ៉ាងលឿន កាលណាគេខំរត់លឿន សាច់ ស្បែក សសៃ ឆ្អឹង ខួរក្នុងឆ្អឹង ក៏ឆេះខ្លោចក្លាយជាផេះអស់តែត្រឡប់កើតជាថ្មីទៀតដូចដើមវិញ

ហើយពុំដែលបានចេញផុតពីទ្វារនរកនោះម្តងណាឡើយ ។ គេសោយទុក្ខក្លាខ្លាំង ខ្លោចផ្សា ដរាបណាបាបកម្មមិនទាន់អស់ ក៏មិនទាន់ស្លាប់ដរាបនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ក្នុងពេលនោះទ្វារខាងក្រោយ ខាងជើង ខាងត្បូងនៃមហានរកនោះក៏បើកចេញ បុរសនោះរត់យ៉ាងលឿន ដើម្បីចេញមកក្រៅ ក្នុងខណៈនោះ សាច់ ស្បែក សរសៃ ឆ្អឹង ។ល។ ខួរក្នុងឆ្អឹង ក៏ឆេះទៅជាផេះ បុរសនោះបានរត់ទៅដល់ទ្វារ តែពុំទាន់បានចេញផុតទ្វារនៃមហានរកៗ ក៏បិទវិញ ។ បុរសនោះ នៅសោយទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សា កាលណាបើបាបកម្មមិនទាន់អស់ ក្នុងកាលនោះក៏មិនទាន់ស្លាប់ឡើយ ។

ម្នាលភិក្ខុទាំងឡាយ ! មានពេលខ្លះ បុរសនោះចេញតាមទ្វារក្រោយនៃមហានរកនោះ ហើយក៏ធ្លាក់ទៅក្នុងរណ្តៅនរកមួយទៀតឈ្មោះ គូថនរក( នរកដែលពោរពេញទៅដោយលាមក) ទៀត។ ម្នាលភិក្ខុទាំងឡាយ ! នៅក្នុងគូថនរកនោះ មានដង្កូវមានមាត់ស្រួចដូចម្ជុល សាច់ ស្បែក ឆ្អឹង សរសៃ ។ល។ ខួរក្នុងឆ្អឹងនៃបុរសនោះ សត្វដង្កូវទាំងនោះខាំស៊ីអស់ពុំមានសល់ឡើយ ។

បុរសនោះសោយទុក្ខក្លាខ្លាំងខ្លោចផ្សា តែបើបាបកម្មមិនទាន់អស់ក៏មិនទាន់ស្លាប់ ។

ម្នាលភិក្ខុទាំងឡាយ ! ពេលបុរសនោះរួចពីគូថនរកទៅក៏ធ្លាក់ចុះក្នុងរណ្តៅនរកមួយទៀតឈ្មោះ ថាកុក្កុលនរក( នរកផេះក្តៅ) ពេលដែលធ្លាក់ទៅហើយ គេសោយទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សា ដរាបណាបាបកម្មនោះមិនទាន់អស់ ដរាបនោះក៏មិនទាន់ស្លាប់ ។

ម្នាលភិក្ខុទាំងឡាយ ! មានព្រៃរកាដ៏ធំខ្ពស់ត្រដួចឡើងមួយយោជន៏ មានបន្លា ១៦ ធ្នាប់ ភ្លើងឆេះក្តៅសព្វ ភ្លឺច្រាលវន្ទាលសន្ធោសន្ធៅតាំងនៅបន្ទាប់គ្នានិងកុក្កុលនរកនោះឯង ។ ពួកនាយនិរយបាល ក៏ប្រើបុរសនោះឱ្យឡើងឱ្យចុះអំពីព្រៃរកានោះ។ បុរសនោះរងទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សាលើដើមរកានោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ព្រៃស្លោសសិតធំតាំងនៅបន្ទាប់គ្នានឹងព្រៃរកានោះឯង ។ បុរសនោះចូលទៅក្នុងព្រៃស្លោសសិតនោះ។ ខ្យល់បក់ស្លឹកស្លោសសិតហើយមកកាត់ដៃកាត់ជើង កាត់ស្លឹកត្រចៀកទាំងច្រមុះ (របស់បុរសនោះ) ។ បុរសនោះសោយ

ទុក្ខវេទនាយ៉ាងក្លាខ្លាំងខ្លោចផ្សាក្នុងព្រៃសសិតនោះ បើបាបកម្ម មិនទាន់អស់ត្រឹមណាក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ! មានស្ទឹងទឹកផ្សា(ប្រៃ)ដ៏ធំតាំងនៅបន្ទាប់នឹងព្រៃស្មៅសសិតនោះឯង ។ បុរសនោះក៏ធ្លាក់ទៅក្នុងស្ទឹងនោះទៀត។ បុរសនោះជួនកាលអណ្តែតបណ្តោយខ្សែទឹក ជួនកាលអណ្តែតច្រាសខ្សែទឹក ជួនកាលអណ្តែតទាំងបណ្តោយទឹកទាំងច្រាសទឹកក្នុងស្ទឹងនោះ។ បុរសនោះរងទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សា បើបាបកម្មមិនទាន់អស់ដរាបណា ក៏មិនទាន់ស្លាប់ដរាបនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ពួកនិរយបាលយកសន្ទូចស្ទូចវាត់ឡើងមកដាក់លើគោក ហើយសួរយ៉ាងនេះថា នែបុរស អ្នកឯងប្រាថ្នាអ្វី ? បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចំរើនខ្ញុំឃ្លានបាយ។ ពួកនិរយបាល ក៏យកកង្វេរដែកក្តៅដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយញាត់នូវដុំទង់ដែងដ៏ក្តៅដែលភ្លើងកំពុងឆេះចូលទៅក្នុងមាត់ ដុំទង់ដែងនោះក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំ ពោះវៀនតូចរបស់បុរសនោះចេញមកខាងក្រោម

បុរសនោះរងទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សាក្នុងនរកនោះ បើបាបកម្ម មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ! ពួកនិរយបាលសួរបុរសនោះទៀតថា នែបុរស អ្នកឯងប្រាថ្នាអ្វី ? បុរសនោះឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំស្រេកទឹកណាស់។ និរយបាល ក៏យកកង្វេរដែកដ៏ក្តៅដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាលមកបើកមាត់បុរសនោះ ហើយបង្ហូកទឹកទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វភ្លឺច្រាលរន្ទាលសន្ធោសន្ធៅទៅក្នុងមាត់ ។ ទឹកទង់ដែងក៏ឆេះ បបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំ ទាំងពោះវៀនតូច របស់បុរសនោះ ចេញមកខាងក្រោម។ បុរសនោះសោយទុក្ខវេទនាក្លាខ្លាំងខ្លោចផ្សា ក្នុងនរកនោះ បើបាបកម្ម មិនទាន់អស់ដរាបណា ក៏មិនទាន់ស្លាប់ដរាបនោះ ។

ម្នាលភិក្ខុទាំងឡាយ (បន្ទាប់មក) ពួកនិរយបាល ក៏បោះទំលាក់បុរសនោះទៅក្នុងមហានរកវិញ។

# ហេតុអ្វីសត្វនរកមិនស្លាប់?

សេចក្តីនេះគួរឱ្យមានសេចក្តីសង្ស័យណាស់ដែរ តាមដែលយើងបានអានពីខាងដើមមក យើងបានដឹងថា សេចក្តីទុក្ខក្នុងនរកធ្ងន់ក្រៃពេកណាស់ មិនអាចនឹងពណ៌នាប្រៀបធៀបនឹងសេចក្តីទុក្ខក្នុងមនុស្សបានឡើយ ចុះហេតុអ្វីក៏សត្វនរកនៅតែមិនស្លាប់ ? សេចក្តីនេះខ្ញុំមិនបានបកស្រាយទេ តែសូមនិមន្តនិង អញ្ជើញមិត្តអ្នកអានទាំងឡាយសិក្សាអំពីការសន្ទនាសាកច្ឆាររវាងព្រះបាទ **មិលិន្ទាធិរាជ** និងព្រះអរហន្តមួយព្រះអង្គព្រះនាម **នាគសេនត្ថេរ** ដូចតទៅ :

ស្តេចមិលិន្ទ្រ:[(១)] (បពិត្រលោកម្ចាស់ សេចក្តីថា : ភ្លើងនរកមានកំដៅក្តៅជាទីបំផុត ជាងភ្លើងជាប្រក្រតីសព្វថ្ងៃនេះ ឯភ្លើងយើងជាប្រក្រតីនេះ ថាបើបុគ្គលនឹងយកដុំថ្មយ៉ាងតូចប្រមាណប៉ុនកំភួនដៃឬ ប៉ុនកំភួនជើងទៅដាក់ដុតក្នុងគំនរភ្លើងយ៉ាងធំៗ អស់ពេលប្រហែលមួយថ្ងៃក៏ដោយ ឯដុំថ្មតូចនោះមិនអាច

---

(១) មិលិន្ទបញ្ហា ត្រង់ បកតិអគ្គិតោនេរយគ្គីនំ ឧណ្ហាការបញ្ហា

រលាយទៅបានឡើយ ចំណែកភ្លើងក្នុងស្ថាននរកនោះ ថាបើមានដុំថ្មយ៉ាងធំប៉ុនផ្ទះធ្លាក់ចុះទៅក្នុងនរកនោះ ដុំថ្មធំនោះឯងក៏នឹងរលាយសាបសូន្យទៅមួយរំពេចមិនខានឡើយ ។ ពាក្យពោលយ៉ាងនេះខ្ញុំមិនជឿសោះឡើយ ម្យ៉ាងទៀតថា សត្វដែលកើតក្នុងស្ថាននរកនោះមានអាយុវែងរាប់ពាន់ឆ្នាំ។ បើភ្លើងនរកនោះមានកំដៅដល់ម្លោះ ហេតុអ្វីក៏មិនឆេះកំទេចសត្វនរកឱ្យស្លាប់មួយរំពេចទៅ ? ម្តេចក៏ឱ្យរស់នៅយូរម្ល៉េះ ? សេចក្តីយ៉ាងនេះខ្ញុំរកជឿមិនបានសោះលោកម្ចាស់ ។

ព្រះនាគសេនត្ថេរៈ បពិត្រមហារាជ! ចុះមហាបពិត្រស្តេចជ្រាបដែរឬថា មេក្ងោក មេមាន់ មេក្រពើ និងមេអណ្តើកទាំងឡាយនោះវាតែងទំពារស៊ី ឬតែងលេបនូវដុំថ្ម ឬដុំគ្រួស (ឬគ្រាប់ស្រូវ) ទាំងឡាយទៅក្នុងពោះវាមែនឬមិនមែនទេមហារាជ ?

ម: **អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចំរើន ! ឯពាក្យនោះមែនយ៉ាងហ្នឹងហើយ ។

ន: **តានិ បន តានិ មហារាជ** បពិត្រមហារាជ ចុះដុំថ្មឬដុំគ្រួស (ឬគ្រាប់ស្រូវ) ដែលចូលទៅក្នុងផ្ទៃ ប្រហែលជារលួយដែរឬអ្វី មហារាជ ?

ម: អាម ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ! ឯដុំទាំងនោះតែងក្តៅរលួយទៅមិនមានសេសសល់ទេ ។

ន: បពិត្រមហារាជ ! ចុះគភ៌គឺពងឬ កូនដែលនៅក្នុងផ្ទៃមេនៃសត្វទាំងនោះប្រហែលជារលួយរលាយអស់ដូចជាដុំថ្ម និង ដុំគ្រួស ( ឬគ្រាប់ស្រូវ ) នោះឬដូចម្តេច ?

ម: ន ហិ ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ! គភ៌ ឬកូនរបស់សត្វទាំងនោះមិនរលួយរលាយឡើយលោកម្ចាស់ ។

ន: តេន ការណេន ព្រោះហេតុដូចម្តេចមហាបពិត្រ ត្រង់ដុំថ្មនិងដុំគ្រួស( ឬគ្រាប់ស្រូវ ) ចេះឆេះរលួយទៅបាន ឯគភ៌ដែលស្ថិតនៅក្នុងពោះនៃសត្វនោះដូចគ្នាដែរ បែរទៅជាមិនរលួយ សេចក្តីនេះគួរឱ្យសង្ស័យដែរមហារាជ តើស្តេចនឹងទ្រង់ជ្រាបយ៉ាងណា?

ម: មញ្ញាមិ ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ! ឯគភ៌របស់សត្វដែលមិនរលួយ ដូចអាហារទាំងពួងនោះ ព្រោះគភ៌នោះអាស្រ័យនៅដោយកំលាំងនៃផលកុសល ឬ អកុសលដែលសត្វនោះបានធ្វើហើយនោះឯង សូមលោកម្ចាស់ជ្រាប ។

ន : ឯវមេវ ខោ មហារាជបពិត្រស្តេចមហារាជ ! សេចក្តីនេះប្រៀបដូចសត្វនរកដែលកើតក្នុងភ្លើងនរក១ ឆេះកំដៅអស់

មួយពាន់ឆ្នាំ ឬច្រើនជាងមួយពាន់ឆ្នាំ ហើយសត្វទាំងនោះមិនរលាយបាត់បង់ជីវិតទៅបាន ក៏មិនមែនដោយហេតុអ្វីឡើយ គឺដោយកំលាំងនៃអកុសលកម្មរបស់សត្វនោះឯង ហើយបានជាសត្វបានកើត បានចំរើននៅក្នុងនរកនោះ វេលាដល់ស្លាប់ក៏ស្លាប់ក្នុងទីនោះផង បពិត្រមហារាជ! សេចក្ដីនេះត្រូវគ្នានឹងសុភាសិតរបស់ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទេសនាទុកមកថាៈ សោ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តី ហោតិ សេចក្ដីថា បើបាបកម្មមិនទាន់អស់ឬមិនទាន់វិនាសទៅដរាបណា សត្វ (នរក) នោះក៏មិនទាន់ធ្វើកាលកិរិយាទៅដរាបនោះសូមទ្រង់ជ្រាប ។

ទ្រង់សំដែងអំពីការដែលសត្វនរកមិនងាយស្លាប់ នោះព្រះនាគសេនត្ថេរបានឧបមាដោយច្រើនទៀតដូចជា មេខ្លាធំ មេខ្លាដំបងជាដើម តែងទំពាស៊ីនូវសាច់និង ឆ្អឹងនៃសត្វម្រឹគទាំង-ឡាយ ហើយសាច់និងឆ្អឹងនៃម្រឹគទាំងអស់នោះតែងរលួយអស់គ្មានសេសសល់ តែកូនដែលនៅក្នុងផ្ទៃនៃមេខ្លាធំ ឬមេខ្លាដំបងនោះ នៅតែមិនស្លាប់ សេចក្ដីនេះយ៉ាងណា រីឯសត្វនរកថ្វីបើភ្លើងនរកក្ដៅដល់ម្លោះនៅតែមិនស្លាប់ ក៏ព្រោះតែកំលាំងនៃបាបកម្មដែលសត្វនរកនោះធ្វើនោះឯង ។ ម្យ៉ាងទៀតដូចជាស្ត្រីដែលមាន

ផ្ទៃពោះតែងបរិភោគនូវបង្អែម ឬចំអាប រឹងខ្លះ ទន់ខ្លះ ហើយអាហារទាំងនោះ ក៏រលួយរលាយក្លាយទៅជាលាមកមូត្រអស់គ្មានសេសសល់ ប៉ុន្តែសត្វដែលអាស្រ័យនៅក្នុងផ្ទៃនោះមិនបានរលាយស្លាប់បាត់បង់ជីវិតឡើយ នេះតើបណ្តាលមកពីកុសលនិងអកុសលជាអ្នកគាំទ្រ សេចក្តីនេះយ៉ាងណា រីឯសត្វនរកថ្វីបើភ្លើងនរកក្តៅយ៉ាងណាក៏ដោយ ក៏នៅតែមិនស្លាប់ ក៏ព្រោះតែបាបអកុសលរបស់សត្វនរកនោះមិនទាន់អស់ក៏យ៉ាងនោះដែរ ។

# ជាននរជានប្បញ្ហា

( **រវាងអ្នកដែលដឹងបុណ្យបាបនិងអ្នកមិនដឹង ពេលដែលធ្វើបាបតើអ្នកណាបាបធ្ងន់ជាង** ) ?

ការដែលលើកយកបញ្ហានេះមកសំដែង ព្រោះខ្ញុំធ្លាប់ឮពពួកជនខ្លះតែងជជែកគ្នាជារឿយៗ ប៉ុន្តែនៅតែមិនដាច់ស្រេចសោះ ហើយក្នុងពេលនេះខ្ញុំក៏មិនចាំបាច់ពន្យល់ឱ្យពិស្តារទេ សូមមិត្តអ្នកអានសិក្សាអំពីការសន្ទនាសាកច្ឆា រវាងស្តេចមិលិន្ទ្រាធិរាជនិង ព្រះនាគសេនត្ថេរ ដូចតទៅៈ

ព្រះបាទមិលិន្ទ្រៈ [១] ស្តេចទ្រង់សួរទៅព្រះនាគសេនត្ថេរថា៖ បពិត្រព្រះថេរៈដ៏ចំរើន ជនពីរនាក់ ជនម្នាក់ជាអ្នកចេះដឹងស្គាល់បុណ្យបាប ហើយទៅប្រព្រឹត្តធ្វើអំពើបាប ជនម្នាក់ទៀតជាអ្នកមិនបានចេះដឹងមិនស្គាល់បុណ្យបាបទេ ហើយទៅប្រព្រឹត្តធ្វើបាបកម្មដូចគ្នា បណ្តាជនទាំងពីរនាក់នោះ តើជនណាបានផលបាបច្រើនជាងជនណាលោកម្ចាស់ ?

ព្រះនាគសេនត្ថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជជិនុំជនទាំងពីរនោះ ជនណាដែលមិនចេះដឹង ជាអ្នកល្ងង់ខ្លៅហើយទៅធ្វើបាបកម្ម ជននោះបានផលបាបច្រើនជាងអ្នកដែលចេះដឹងសូមទ្រង់ជ្រាប ។

មៈ បពិត្រព្រះថេរៈដ៏ចំរើន បើដូច្នោះទោសនោះប្លែកគ្នានឹងទោសក្នុងបច្ចុប្បន្ននេះលោកម្ចាស់ ឯទោសក្នុងបច្ចុប្បន្ននេះថាបើជនណាជារាជបុត្រ ឬជារាជមហាមាត្យ ជាអ្នកដឹងការខុសត្រូវធ្ងន់ស្រាល ហើយទៅប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗឱ្យខុសចាករាជប្បញ្ញត្តិហើយ យើងខ្ញុំត្រូវធ្វើទោសដាក់ទណ្ឌកម្មដល់ជនទាំងនោះ ជាទ្វេគុណលោកម្ចាស់ ។

---

(១) មលិន្ទប្បញ្ហ ភាគទី២

ន: បពិត្រសម្តេចមហារាជ ចុះព្រះអង្គទ្រង់ព្រះយោបល់ឃើញយល់ក្នុងសេចក្តីនេះដូចម្តេចទៅ អាត្មាភាពនឹងប្រៀបជាសេចក្តីថ្វាយឱ្យជាក់ច្បាស់ថា ដូចជាជនពីរនាក់ ជនម្នាក់ជាអ្នកល្ងង់ខ្លៅ មិនដឹង មិនស្គាល់នូវដុំដែកមានភ្លើងកំពុងឆេះក្រហមរន្ទាលច្រាលឆ្អៅ គួរឱ្យញញើតស្ញើបជាពន្លឹកពេក ហើយជននោះយកដៃទៅចាប់កាន់ដោយស៊ប់សួនចំពោះត្រង់ដុំដែកនោះ ដោយសេចក្តីយល់ខុសថាជាវត្ថុឯទៀតផ្សេង ឯជនម្នាក់ទៀតជាអ្នកដឹងប្រាកដថា ដុំក្រហមនោះចំពោះជាដុំដែកមានភ្លើងកំពុងឆេះក្រហមរន្ទាលច្រាលឆ្អៅ តែត្រូវការនឹងលូកទៅចាប់យកដុំដែកនោះដែរ ក៏បណ្តាជនទាំងពីរនាក់នោះ តើជនណានឹងត្រូវគ្រោះរលាករលួយដៃនោះច្រើនជាងជនណា មហាបពិត្រ ?

ម: បពិត្រលោកម្ចាស់ដ៏ចំរើន ជនណាដែលមិនដឹង មិនស្គាល់នូវដុំដែកក្តៅហើយ យកដៃទៅចាប់កាន់ដោយស៊ប់សួនជននោះនឹងត្រូវកំដៅយ៉ាងខ្លាំងដល់រលាករលួយដៃមិនខាន សូមលោកម្ចាស់ជ្រាប ។

ន: បពិត្រមហារាជ សេចក្តីនេះមានគូរនាដូចម្តេចមិញថាមានគូរនាដូចជាជនដែលជាអ្នកមិនដឹងការខុសត្រូវធ្ងន់ស្រាល

ហើយទៅប្រព្រឹត្តធ្វើអំពើអាក្រក់ ជននោះឯងនឹងបានផលបាបច្រើនជាងអ្នកដែលចេះដឹងនោះ សូមស្តេចជ្រាប ។

មៈ លោកម្ចាស់ប្រសប់ប្រៀបប្រាយអធិប្បាយ ជាសេចក្តីងាយស្តាប់ពេកណាស់ ។

# បំនកស្រាយចំងល់ខ្លះៗ

*សំនួរ* : តើស្តេចយមរាជមានដែរឬទេ ? ឬក៏គ្រាន់តែជានិម្មិតឱ្យឃើញទៅតាមកម្មរបស់សត្វទេដឹង ?

*ចំលើយ* : ស្តេចយមរាជគឺមានពិតប្រាកដក្នុងលោក មិនមែនគ្រាន់តែជាកម្មនិម្មិតទេ ។

*សំណួរ* : តើស្តេចយមរាជនោះបានធ្វើកម្មអ្វីបានជាកើតក្នុងទីនោះ ?

*ចំលើយ* : កម្មដែលគាត់កសាងនោះគឺ កាលនៅជាមនុស្សគាត់ធ្វើបុណ្យខ្លះធ្វើបាបខ្លះ, ត្រេកអរនឹងគេធ្វើបុណ្យខ្លះ ត្រេកអរនឹងគេធ្វើបាបខ្លះ ។ ដូច្នេះហើយ បណ្តាលឱ្យគាត់បដិសន្ធិជាស្តេចយមរាជ។

*សំណួរ* : តើចំពោះស្តេចយមរាជផ្ទាល់ មានការសោយសុខ ឬ ទុក្ខយ៉ាងណាដែរ ?

*ចំលើយ* : ស្តេចនោះ គឺជាស្តេចវិមានិកប្រេត ព្រោះវិមា-និកប្រេតនោះ ជួនកាលសោយទិព្វសម្បត្តិ មានដើមកប្បព្រឹក្សជាទិព្វ ឧទ្យានជាទិព្វ ស្រះបាំជាទិព្វ សោយសុខនៅក្នុងទិព្វវិមាននោះ ប៉ុន្តែជួនកាលក៏ក្លាយទៅជាស្តេចយមរាជសោយកម្មវិបាក ។

*សំណួរ* : ចុះចំណែកពួកនាយនិរយបាលឬយមបាលនោះ តើ ពួកគេបានធ្វើកម្មអ្វីបានជាទៅកើតក្នុងទីនោះ ?

*ចំលើយ* :កាលពួកគេកើតជាមនុស្សនោះ បានត្រេកអរនឹងគេធ្វើបុណ្យខ្លះ ត្រេកអរនឹងគេធ្វើបាបខ្លះ ទើបបណ្តាលឱ្យពួកគេទៅកើតក្នុងកំណើតបែបនេះ ។

*សំនួរ* :តើសត្វលោកទាំងអស់ដែលស្លាប់ទៅ ត្រូវស្តេចយមរាជសួរចំលើយកាត់ក្តីទាំងអស់គ្នាឬ ?

*ចំលើយ* :មិនមែនដូច្នោះទេ សេចក្តីនេះគឺថា បើសត្វណាបានធ្វើបុណ្យច្រើន វេលាដែលស្លាប់ក៏ត្រូវបដិសន្ធិនៅក្នុងស្ថានម-នុស្សឬស្ថានសួគ៌ទេវលោកតែម្តង។ ចំណែកសត្វណាបានធ្វើបាប

កម្មច្រើន ក៏ត្រូវធ្លាក់នរកតែម្តង ព្រះយមរាជមិនចាំបាច់សួរចំ-លើយទេ ។

*សំណួរ* : តើពេលដែលនាយនិរយបាល នាំសត្វនរកមកដល់ស្តេចយមរាជក៏ចាប់ផ្តើមសួរនូវទេវទូតទាំង៥នោះភ្លាម ឬ ក៏មានសួរអ្វីផ្សេងទៀតដែរ ?

*ចំលើយ* : មិនមែនទេ មុននឹងសួរនូវទេវទូតទាំង ៥ ស្តេចយមរាជបានសួរអំពីអំពើកម្មរបស់សត្វ កាលនៅជាមនុស្សថា តើធ្លាប់បានធ្វើបុណ្យ សន្សំកុសល បំរើមាតា បិតាដែរឬទេ ? បើសត្វនោះនឹករលឹកដល់បុណ្យកុសលដែលខ្លួនបានធ្វើនឹងឱ្យរួចទោស បើសត្វនោះនឹកមិនឃើញទេ ទើបសួរនូវទេវទូតទាំង ៥ ទៀត ។

*សំនួរ* : តើស្តេចយមរាជនោះមានចិត្តកាចសាហាវដូចជាគេលេងរឿងល្ខោនដែរឬទេ ?

*ចំលើយ* :មិនមែនទេ បើសិនជាគាត់មានចិត្តកាចសាហាវនោះ គាត់មិនចាំបាច់សួរនូវទេវទូតទាំង ៥ នោះឡើយ ។

*សំនួរ* : តើស្តេចយមរាជនោះតែងមានសេចក្តីត្រិះរិះយ៉ាងណាទៅ ?

*ចំលើយ* ៖ គាត់តែងមានសេចក្តីត្រិះរិះល្អណាស់ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា៖

ម្នាលភិក្ខុទាំងឡាយ រឿងរ៉ាវធ្លាប់មានមកហើយ ថាព្រះយមរាជមានសេចក្តីត្រិះរិះដូច្នេះថា បានឮថា សត្វទាំងឡាយណាធ្វើបាបកម្មក្នុងលោក សត្វនោះឯងរមែងត្រូវគេធ្វើកម្មករណ៏ផ្សេងៗ មានសភាពយ៉ាងនេះ ឱហ្ន៎ អាត្មាអញសូមឱ្យបានអត្តភាពជាមនុស្ស ឱ្យទាន់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងក្នុងលោក សូមឱ្យអាត្មាអញចូលទៅអង្គុយជិតព្រះមានព្រះភាគអង្គនោះ បើព្រះមានព្រះភាគអង្គនោះទ្រង់សំដែងធម៌ប្រាប់អាត្មាអញ សូមឱ្យអាត្មាអញយល់ច្បាស់នូវធម៌របស់ព្រះមានព្រះភាគអង្គនោះ។ ម្នាលភិក្ខុទាំងឡាយ ឯតថាគតមិនមែនបានស្តាប់រឿងនោះឯងអំពីសមណៈ ឬព្រាហ្មណ៏ដទៃណាមួយហើយ( នាំមក)សំដែងទេ តាមដែលពិតនោះ តថាគតសំដែងរឿងដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង យល់ខ្លួនឯងតែម្យ៉ាង (ដូចជាទេវទូតសូត្រនិង ការសោយទុក្ខក្នុងនរកនោះជាដើម) ។

# និគមគាថា

លុះព្រះមានព្រះភាគទ្រង់ត្រាស់នូវ(ទេវទូតសូត្រ)ចប់ហើយ ទើបព្រះអង្គទ្រង់ត្រាស់និពន្ធគាថានេះតទៅថា៖

**មាណពទាំងឡាយណាដែលយមរាជដាស់តឿន**
**ដោយទេវទូតទាំងឡាយហើយ ក៏នៅតែប្រមាទ**
**មាណពទាំងនោះឯង ជាអ្នកបាននូវកាយថោកទាប**
**រមែងសោកសៅអស់កាលជាយូរអង្វែង ចំណែក**
**មាណពណាក្នុងលោកនេះជាសប្បុរស មានសន្តាន**
**ស្ងប់រម្ងាប់ ដែលយមរាជដាស់តឿន ដោយទេវទូត**
**ទាំងឡាយហើយ តែងមិនប្រមាទក្នុងអរិយធម៌**
**ក្នុងកាលណាឡើយ រមែងឃើញនូវភ័យក្នុង**
**ឧបាទាន ជាហេតុកើតឡើងនៃជាតិនិង មរណៈ**
**តែងចុះចិត្តស៊ប់ក្នុងព្រះនិព្វានជាធម្មជាតិអស់ទៅ**
**នៃជាតិនិងមរណៈ ព្រោះមិនប្រកាន់មាំ មាណពនោះ**
**ឯង ជាអ្នកដល់នូវទីនៅដ៏ក្សេម មានសេចក្តីសុខ**

រលត់កិលេសក្នុងបច្ចុប្បន្ន ជាអ្នកឆ្លងផុតនូវពៀរ

និងភ័យទាំងពួង បានឆ្លងផុតនូវទុក្ខទាំងពួង

បានឆ្លងផុតនូវទុក្ខទាំងពួង។

# សំណោករបស់យាយ

នាម **សាន សុជា** សូមលើកហត្ថា សរសេរកូនច្បាប់
ជូនញាតិសន្តាន ជាទីសណ្តាប់ បើមិនគួរគាប់
សូមអត់ទោសពៅ ។

នេះនឹងបរិយាយ ពីការសោកស្តាយ មនុស្សចាស់ស្រីៗ
ដែលគាត់ស្រណោះ កាលនៅក្មេងវ័យ តែងជាកាព្យខ្លី
មានន័យតទៅ ។

ស្តាយអើយសែនស្តាយ ស្តាយរូបរាងកាយ ដែលចាស់ហួសទៅ
កាលនៅក្រមុំ រូបគ្មានហ្មងសៅ បុរសទូទៅ
ចែចូវគ្រប់គ្នា ។

ស្តាយអើយសែនស្តាយ ស្តាយសក់រសាយ រលោងអស្ចារ្យ
ដល់ពេលខ្ញុំចាស់ គេលែងត្រូវការ សូម្បីតែតា
ក៏លែងមើលដែរ ។

ស្តាយអើយសែនស្តាយ ស្តាយធ្មេញទាំងឡាយ រឹងមាំគួរដែរ
ដល់ពេលខ្លួនចាស់ ក្រឡះប្រួលប្រែ បាក់ជាហូរហែ
កែក៏មិនបាន ។

ស្តាយអើយសែនស្តាយ អាណិតរូបកាយ ជរារុញច្រាន
ដល់ពេលខ្លួនចាស់ ភាពស្រស់ប៉ុន្មាន ចោរជរាបាន
លួចយកទាំងអស់ ។

ស្តាយអើយសែនស្តាយ សាច់ស្បែកទាំងឡាយ ហ្មត់ល្អឥតខ្ចោះ
ដល់ពេលខ្លួនចាស់ ជ្រួញស្វិតកក្រោះ ពួកអ្នកកំឡោះ
គេលែងត្រូវការ ។

ស្តាយអើយសែនស្តាយ វង់ភក្ត្រឆើតឆាយ គ្មានទាស់ត្រង់ណា
ប្រុសណាឃើញហើយ តែងលង់ចិន្តា សូម្បីអាចារ្យ
ក៏សូត្រធមិខុស ។

ស្តាយអើយសែនស្តាយ ក្រចកទាំងឡាយ ភ្លឺល្អទាំងអស់
សមនិងម្រាមដៃ ល្វតល្វន់ឥតខ្ចោះ ឥឡូវប្រែអស់
លែងស្រស់ទៀតហើយ ។

ស្តាយនេត្រាខ្ញុំ កាលនៅក្រមុំ ភ្នែកពុំព្រិលឡើយ
ដល់ពេលខ្លួនចាស់ មើលលែងច្បាស់ហើយ ជាងវ៉ែនតាអើយ
ជួយលែលកផង ។

កាលរូបនៅក្មេង ឱ្យតែខ្ញុំតែង រូបកាយម្តងៗ
ឆ្លុះមើលកញ្ចក់ សែនស្រស់ឥតហ្មង ៦០ឆ្នាំកន្លង
លោកញ្ចក់ហើយ ។

កាលនៅក្រមុំ រូបសម្រស់ខ្ញុំ សមគ្មានទាស់ឡើយ
សូម្បីព្រះសង្ឃ ក៏មិនព្រងើយ មិនសង្រួមឡើយ
ហេងស៊យដាច់សីល ។

និយាយយ៉ាងនេះ មិនមែនត្រិះរិះ ដោយគំនិតខិល
មិនមែនបង្អាប់ លោកយាយទ្រង់សីល ដោយមាត់រអិល
ចេះតែថាទេ ។

តែថាភាពពិត តែមានជីវិត មិនថាយើងគេ
កើតមកត្រូវចាស់ គ្មាននៅសល់ទេ ថៅកែខ្ញុំគេ
ចាស់ឥតសល់សោះ ។

បន្ទាប់ពីចាស់ យើងបានឃើញច្បាស់ ថាស្លាប់ទាំងអស់
បិតាភរិយា ទ្រព្យារបស់ យកមិនបានសោះ
បោះចោលទទេ ។

ដូច្នេះគួរគិត ធ្វើទុកក្នុងចិត្ត រួតរះគ្មាន់គ្នេរ
ប្រញាប់សាងទាន កាន់សីលនឹងគេ កុំនៅទំនេរ
ដេរកូននៅផ្ទះ ។

រៀនព្រះសទ្ធម្ម ដើម្បីអប់រំ ចិត្តឱ្យល្អល្អះ
កុំនៅអែអង់ រង់ចាំខ្លួនចាស់ ដល់ស្លាប់លែងច្បាស់
ថាទាស់ចាស់ជ្រុល ។

ធម៌ជាឱសថ ពិសេសបំផុត បំបាត់ជាតិពុល
បើសត្វណាត្រាប់ ច្បាប់ព្រះពន្យល់ សត្វនោះនឹងដល់
ព្រះនិព្វានហោង ។

ព-ស២៥៤៥

ថ្ងៃអាទិត្យ ទី ១៥ ខែ កក្កដា ——————

គ-ស ២០០២

**ដោយភិក្ខុ វជិរប្បញ្ញោ សាន សុជា**

# មានះរបស់តា

ពោលតែរឿងយាយ ១គាត់ថា	ម្ដេចចំណែកតាមិនបរិយាយ
រឿងនេះបាក់ដូចជាមើលងាយ	ថាឱ្យតែយាយដូចមិនត្រូវ ។
រឿងយាយគាត់ចោទពិតជាសម	ខ្ញុំនឹងខិតខំកែតម្រូវ
សរសេរតម្រាចារប៉ះប៉ូវ	ទោះខុសឬត្រូវសូមមេត្តា ។
រឿងតាជារឿងដាច់ដោយឡែក	គាត់ច្រើនពឹងផ្អែកលើវិជ្ជា
ដែលគាត់ធ្លាប់រៀនធ្លាប់សិក្សា	សូម្បីទេសនាក៏លែងស្ដាប់ ។
តាខ្លះពីក្មេងគាត់ធ្លាប់បួស	ច្រើនតែចេះហួសតម្រាច្បាប់
អាងយសអាងស័ក្ដិល្បីសូរសព្ទ	លែងចេះត្រងត្រាប់ច្បាប់ព្រះដើម ។
អ្នកខ្លះធ្លាប់រៀនធ្លាប់បានបួស	ទេសនាពិរោះយសសម្បើម
សឹកមួយរំពេចភ្លេចធាតុដើម	ល្វីល្វើជ្រួលជ្រើមឡប់លែងជា ។
ខ្លះរឹតតែដឹងរឹតចចេស	អ្នកផងគ្មានចេះជាងអាត្មា
អាងនាមអាងឈ្មោះជាអាចារ្យ	ប្រាជ្ញលោកទេសនាថាមិនត្រូវ ។
ខ្លះរឹតតែល្បីរឹតតែល្ងើ	ជ្រប់ងប់ភ្លឺភ្លើដើរខុសផ្លូវ
ឃើញអ្នកដទៃទាបដូចស្មៅ	សំដៅថាមានតែអាត្មា ។
មិននិយាយ លោកយាយក៏ដឹង	ថាសព្វថ្ងៃហ្នឹងវាយ៉ាងណា
ការរៀនឬស្ដាប់ព្រះធម្មា	យាយច្រើនជាងតារាល់តែថ្ងៃ ។
រឿងនេះនិយាយតាមគំហើញ	ដែលខ្ញុំធ្លាប់ឃើញក្នុងលោកិយ
សូមលោកយាយជួយវិនិច្ឆ័យ	ថាជន្លេនជីវាយ៉ាងណា ។

វារស់នៅក្នុងត្រឡោកផ្កាប់ អួតខុសសណ្ដាប់ខុសតម្រា
ក្បាលប៉ះត្រឡោកនោះកាលណា សំគាល់អាត្មាធំជាងមេឃ ។
ឬដូចកង្កែបក្នុងកូនថ្លុក បានត្រឹមសំកុកតំហាកស្រែក
ចំកោងអួតខ្លួនជាអនេក លើដីក្រោមមេឃគ្មានអ្នកដល់ ។
រឿងនេះមិនមែនចេះតែស្តី ពោលពាក្យព្រៃផ្សៃគ្មានហេតុផល
សូមលើកគ្រឿងអាងមកតម្កល់ **ឆឹង តាន** ពន្យល់ដូច្នេះថា ។
មានះជើងឯកប៉ែកខាងរឹង ល្ងង់ម្ល៉ឹងមិនព្រមញ៉មអ្នកណា
មានះនេះមានជរាបណា ប្រយោជន៍ខ្លឹមសារត្រូវអន្តរាយ ។
ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះចុះ អស់លោកសប្បុរសផងទាំងឡាយ
ខ្ញុំមិនមែនពោលពាក្យឡេបខាយ មើលងាយតាៗទាំងអស់ទេ ។
និយាយសំដៅតាៗខ្លះ ដែលគាត់មានះឯណោះទេ
បើមានប៉ះពាល់សូមកុំជេរ គិតគូរកែប្រែប្រសើរជាង ។

**ដោយភិក្ខុ ឧបរិយេញ្ញោ សាន សុជា**

# មនុស្សរបស់វត្ត

ហៃពួកយុវជនអ្នកកំសត់ បើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ យប់ថ្ងៃហួសទៅឥតប្រយោជន៍ ។
គួរអ្នកកុំភ្លេចវត្តលំនៅ ទោះអ្នកចេញទៅឆ្ងាយស្រឡោច
គួរដឹងគុណវត្តកុំបង្ហោច ប្រយោជន៍និងផលផ្តល់ពុំខាន ។
បើមានគេសួរពីការរៀន ចំណេះរបៀនទាំងប៉ុន្មាន
អ្នកកុំនិយាយបង្វែងដាន ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
កុំពោលបង្អួតពួកស្រីៗ ត្រូវស្តីតាមត្រង់កុំបីភ្ញាត់
បំផ្លែងបំភ្លើសបំភ្លេចវត្ត ក្រែងទោសតាមទាត់ឱ្យវិនាស ។
បាយវត្តជាភោជន៍មានព្រលឹង គួរនឹករំពឹងកុំភ្លេចគុណព្រះ
នាម៉ឺនមន្ត្រីមកពីរាស្ត្រ គឺរាស្ត្រឡើងទៅជាមន្ត្រី ។
បាយផ្ទះបាយវត្តដូចតែគ្នា ចំអែតអាត្មាដោយចំណី
ឆ្អែតហើយរៀនសូត្រយល់សេចក្តី មុនីកើតថ្មីដោយសារវត្ត ។
សាធុ ! សូមឱ្យអ្នកបានសុខ និរទុក្ខនិរភ័យសិរីភទ្រ
ជាជនសប្បុរសរបស់រដ្ឋ មានបែបមានបទប្រសើរពោង ។

ដកស្រង់ពី កម្ពុជសុរិយា